មជ្ឈមណ្ឌលឯកសារកម្ពុជា

**ឡាច កប , ភេទប្រុស** K09328 **(បាត់ខ្លួន)**

**ប្រជាជនចាស់ នៅសហករណ៍វត្តចាស់**

**សម្ភាសន៍ជាមួយ ឡាត់ សុខ, អាយុ ៦១ ឆ្នាំ“ត្រូវជាប្អូនស្រី”**

**នៅភូមិជ្រៃជើង ឃុំជ្រៃជើង ស្រុកមោង ខេត្តបាត់ដំបង**

**ថ្ងៃទី ១០ កក្កដា ឆ្នាំ២០០៦**

**សម្ភាសន៍ដោយៈ វ៉ា នៃវ៉ាន់**

នៃវ៉ាន់: អ៊ំអត់ទោសអ៊ំ ឈ្មោះអីដែរ?

សុខ: ខ្ញុំឈ្មោះ ឡាត់ សុខ ។

នៃវ៉ាន់: សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយ?

សុខ: ខ្ញុំអាយុ ៦១ ។

នៃវ៉ាន់: ៦១ឆ្នាំ..

សុខ: ចា៎!

នៃវ៉ាន់: អ៊ំ កើតឆ្នាំអីដែរ?

សុខ: ឆ្នាំច ។

នៃវ៉ាន់: បាទ! លោកអ៊ំមានស្រុកកំណើតកើតជានៅ អីណាដែរ?

សុខ: ខ្ញុំនៅគាលាស់ ។

នៃវ៉ាន់: នៅភូមិអីដែរ?

សុខ: នៅហ្នឹងគេហៅភូមិគាលាស់ ឃុំគាលាស់ ។

នៃវ៉ាន់: ស្រុក...?

សុខ: ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

នៃវ៉ាន់: ចុះបច្ចុប្បន្នអ៊ំរស់នៅក្នុងភូមិឃុំអីដែរ?

សុខ: ខ្ញុំនៅឃុំជ្រៃ ភូមិជ្រៃជើង ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

នៃវ៉ាន់: បាទ! អ៊ំប្តូរមៅនៅភូមិឃុំនេះតាំងពីឆ្នាំណាដែរ?

សុខៈ តាំងពីឆ្នាំបែកម៉ោ ៧៨ ហ្អែ៎?

ឆៃវ៉ាន់ៈ ៧៩..! អូតាំងពីពី ៧៩ ម៉ោអ៊ំ ម៉ោនៅនេះ...?

សុខៈ ចា៎! ម៉ោហ្នឹងរហូត ។

ឆៃវ៉ាន់ៈ ម៉េចបានប្ដូរម៉ោនៅនេះ?

សុខៈ ព្រោះអីនេះស្រុកភូមិខ្ញុំម៉ែក្មេកខ្ញុំ ។

ឆៃវ៉ាន់ៈ អូ..ស្រុកភូមិម៉ែក្មេកហ្អែស៎...

សុខៈ ចា៎! ម៉ែក្មេកខ្ញុំនៅដីណឹងភូមិណឹង ។

ឆៃវ៉ាន់ៈ បាទ! ចុះឪពុកម្ដាយអ៊ំឈ្មោះអីដែរ?

សុខៈ ឈ្មោះស៊ឺ កាយ ។

ឆៃវ៉ាន់ៈ មិនមែនឈ្មោះ ឡាច ឡាត់ទេ?

សុខៈ អូភ្លេចប្រឡំ ឪពុកឈ្មោះ ឡាច ឡាត់ ។

ឆៃវ៉ាន់ៈ ចុះម្ដាយ?

សុខៈ ម្ដាយឈ្មោះ ស៊ឺ កាយ ។

ឆៃវ៉ាន់ៈ សព្វថ្ងៃគាត់ទាំងពីរនាក់ស្លាប់អស់ហើយ?

សុខៈ គាត់ស្លាប់យូរហើយ ។

ឆៃវ៉ាន់ៈ តាំងមុនខ្មែរក្រហមទៀតហ្អែស៎?

សុខៈ អត់ទេម្ដាយខ្ញុំស្លាប់សម័យខ្មែរក្រហមឆ្នាំ ៧៦ ។

ឆៃវ៉ាន់ៈ ចុះឪពុកស្លាប់មុន?

សុខៈ ចា៎!

ឆៃវ៉ាន់ៈ ម្ដាយស្លាប់ជំនាន់ខ្មែរក្រហមណឹងស្លាប់ដោយសារអីដែរ?

សុខៈ គាត់ឈឺ..រាក ។

ឆៃវ៉ាន់ៈ ចុះអ៊ំមានបងប្អូនប៉ុន្មាននាក់?

សុខៈ ខ្ញុំមានបងប្អូន ៧ នាក់ ។

ឆៃវ៉ាន់ៈ ៧ នាក់គិតទាំងអ៊ំ ហ្អែស៎?

សុខៈ ចា៎!

ឆៃវ៉ាន់ៈ ស្រីប៉ុន្មាន? ប្រុសប៉ុន្មានដែរអ៊ំ?

សុខៈ ស្រី ២ ប្រុស ៥ ។

នៃរ៉ាន់ៈ បងទី ១ ឈ្មោះអីដែរអ៊ំ?

សុខៈ បងប្រុសទី ១ ឈ្មោះ ឡាត់ គឹម ។

នៃរ៉ាន់ៈ ប្រុសបក្រ៏ស្រី?

សុខៈ ប្រុស ។

នៃរ៉ាន់ៈ គាត់នៅរស់ឬក៏ស្លាប់ហើយ?

សុខៈ គាត់ស្លាប់ហើយ ។

នៃរ៉ាន់ៈ ស្លាប់តាំងដឹនាន់ណា?

សុខៈ ស្លាប់កាលមួយឆ្នាំមុននេះ ។

នៃរ៉ាន់ៈ ចុះទី ២?

សុខៈ ទី ២ឈ្មោះ ឡាត់ គួម ។

នៃរ៉ាន់ៈ ស្រីឬប្រុស?

សុខៈ ស្រី ។

នៃរ៉ាន់ៈ គាត់សព្វថ្ងៃនោរស់ឬក៏ស្លាប់?

សុខៈ នៅរស់ ។

នៃរ៉ាន់ៈ រស់នៅឯណាដែរ?

សុខៈ នៅជិតគ្នាណឹង ។

នៃរ៉ាន់ៈ ចុះទី ៣?

សុខៈ ទី ៣ឈ្មោះ ឡាត់ កបណឹង ។

នៃរ៉ាន់ៈ អូ...កបណឹងកូនទី ៣?

សុខៈ ចា៎!

នៃរ៉ាន់ៈ ចុះទី ៤?

សុខៈ ទី៤ ឡាត់ កើត ។

នៃរ៉ាន់ៈ ស្រីឬប្រុស?

សុខៈ ប្រុស ។

នៃរ៉ាន់ៈ សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់?

សុខៈ ស្លាប់ ។

នៃរ៉ាន់ៈ ស្លាប់ជំនាន់ណាអ៊ំ ?

សុខៈ ស្លាប់តាំងជំនាន់មិនអាពតទៀអីនោះ ។

នៃរ៉ាន់ៈ អូ..គាត់ឈឺហ្អែស៎ ?

សុខៈ ចា៎ !

នៃរ៉ាន់ៈ ចុះទី ៥ ?

សុខៈ ទី ៥ ឈ្មោះ ឡាត់ ធឿន ។

នៃរ៉ាន់ៈ ធឿនហ្អែស៎ ?

សុខៈ ធឿន ។

នៃរ៉ាន់ៈ បាទ ! សព្វថ្ងៃគាត់នៅរស់ឬក៏សាប់អ៊ំ ?

សុខៈ អូ..អាធឿននៅរស់នៅឡើយទេ ។

នៃរ៉ាន់ៈ រស់នៅអីណាអ៊ំ ?

សុខៈ រស់នៅក្រៅអីណោះ ។

នៃរ៉ាន់ៈ នៅអាមេរិក...?

សុខៈ នៅបារាំង ។

នៃរ៉ាន់ៈ ចុះទី៦ ?

សុខៈ ទី ៦ ឡាត់ ធី ។

នៃរ៉ាន់ៈ ធីស្រីឬប្រុស ?

សុខៈ ប្រុស ។

នៃរ៉ាន់ៈ សព្វថ្ងៃនៅរស់ឬក៏ស្លាប់ ?

សុខៈ ស្លាប់ ។

នៃរ៉ាន់ៈ ស្លាប់ជំនាន់ណាអ៊ំ ?

សុខៈ ស្លាប់ជំនាន់មុនណឹងទៀត ។

នៃរ៉ាន់ៈ មុនខ្មែរក្រហមទៀត ?

សុខៈ ចា៎ !

នៃរ៉ាន់ៈ អីចឹងអ៊ំក្រោយគេ ?

សុខៈ អូ..ខ្ញុំអត់ចាំទាន់មានឈ្មោះទេអីចឹង...

នៃរ៉ាន់ៈ ទី៤បានអុំ...

សុខៈ ដឹងបានប៉ុន្មាននាក់ហើយ?

នៃរ៉ាន់ៈ បាន ៧ នាក់ត្រូវហើយអុំ...ប្រុស ៥ ស្រី ២ ។

សុខៈ ចា៎!

នៃរ៉ាន់ៈ អុំហើយ និងកបណឹងអុំត្រូវជាប្អូនស្រីគាត់បង្កើតហ្អែស៎?

សុខៈ ចា៎!

នៃរ៉ាន់ៈ អុំកបណឹងអុំចាំថាគាត់កើតឆ្នាំអីដែរអុំ?

សុខៈ កើតឆ្នាំមមែ..

នៃរ៉ាន់ៈ អូ..មមែណឹងពពែរហ្អែស៎?

សុខៈ មមែពពែរបងខ្ញុំប៉ុន្មានឆ្នាំអីណោះ ។

នៃរ៉ាន់ៈ បើមើទល់ឥឡូវគាត់ប្រហែលអាយុប៉ុន្មានឆ្នាំហើយអុំ?

សុខៈ មើស...មមែ,វក,រកា,ច បង ៣ ឆ្នាំ ។

នៃរ៉ាន់ៈ ប្រហែល ៦៤ ហើយនែស៎?

សុខៈ ប្រហែល ៦៤ ហើយ ។

នៃរ៉ាន់ៈ ដូចថាកាលពីក្មេងៗគាត់បានរៀនសូត្រនៅអីណាដែរ?

សុខៈ គាត់រៀននៅតាលាស់ណឹងដែរ ។

នៃរ៉ាន់ៈ គាត់រៀននៅសាលាណា?

សុខៈ នៅបឋមសិក្សាតាលាស់ណឹង... ។

នៃរ៉ាន់ៈ ចុះគាត់មានទៅរៀននៅឯណាដែរ?

សុខៈ ដល់ពេលរៀនៅណឹងចប់ទៅរៀននៅបាត់ដំបង ។

នៃរ៉ាន់ៈ ពេលណឹងគាត់ជាប់បាក់ឌុបហើយឬនៅ?

សុខៈ អត់ទាន់ទេ កាលណឹងគាត់រៀនថ្នាក់ទី ៥ ...ទី ៤,ទី ៣ ឌីប្លូមហើយ ។

នៃរ៉ាន់ៈ បាទ! គាត់រៀនដល់ថ្នាក់ទី ៥?

សុខៈ ចា៎! ទី ៥ ចាស់នោះ ។

នៃរ៉ាន់ៈ គាត់ទៅរៀននៅសាលាណាបាត់ដំបងណឹង?

សុខៈ កាលណឹងរៀននៅសាលាសោហ៊ីរ...។

នៃរ៉ាន់ៈ សោហ៊ី?

សុខៈ ចាំ! ព្រោះអីសោហ៊ីរគេបើកសាលាធំហ្មស់?

នៃរ៉ាន់ៈ បាទ! គាត់រៀនបានត្រឹមថ្នាក់ទី ៩?

សុខៈ ចាំ!

នៃរ៉ាន់ៈ យ៉ាងម៉េចបានគាត់ឈប់រៀនត្រឹមថ្នាក់ទី ៩អីចឹង?

សុខៈ ឈប់កាលណឹងមិនដឹងយ៉ាងម៉េច...ដូចថាមានមូលហេតុដូចថាទៅមុខមិនរួច?

នៃរ៉ាន់ៈ អូ...គាត់រៀនអត់សូវពូកែ?

សុខៈ ចាំ!

នៃរ៉ាន់ៈ គាត់ឈប់រៀនណឹងអឺស្មានមើលប្រហែលជាឆ្នាំណា?

សុខៈ ឈប់រៀនណឹងមិនដឹងឆ្នាំណាទេភ្លេចបាត់ហើយ ។

នៃរ៉ាន់ៈ កាលគាត់ឈប់រៀនណឹងគាត់អាយុប្រហែលប៉ុន្មានហើយ?

សុខៈ កាលណឹងភ្លេចអស់ហើយ...មិនបានចាមផង ។

នៃរ៉ាន់ៈ អីចឹងគាត់រៀនត្រឹមថ្នាក់ទី ៩ ពេលគាត់ឈប់ហើយគាមៅស្រុកភូមិវិញ?

សុខៈ ចាំ! មៅផ្ទះវិញ ។

នៃរ៉ាន់ៈ ដល់ពេលមៅផ្ទះវិញគាត់ធ្វើអីទៅ?

សុខៈ អត់ធ្វើអីផង...ធ្វើស្រែ ។

នៃរ៉ាន់ៈ រៀនបានត្រឹមថ្នាក់ទី ៩ត្រឡប់មៅផ្ទះវិញធ្វើស្រែជាមួយឪពុកម្ដាយ?

សុខៈ ដូចថាអត់មានលទ្ធភាពអីទៅធ្វើការកើតហ្មស់កាលណឹង ។

នៃរ៉ាន់ៈ បាទ!

សុខៈ ធ្វើស្រែរកប្រពន្ធបណ្ដោយ..។

នៃរ៉ាន់ៈ បាទ! គាត់ត្រឡប់មៅស្រុកភូមិប្រហែលរយៈពេលប៉័ន្មានបានគាត់មានប្រពន្ធ?

សុខៈ មិនដឹងប៉ុន្មានឆ្នាំទេភ្លេចហើយ ។

នៃរ៉ាន់ៈ ពេលគាត់ឈប់រៀនណឹងពេលណឹងគេរដ្ឋប្រហារហ្អែស់?

សុខៈ នៅឡើយទេ ។

នៃរ៉ាន់ៈ គាត់ឈប់រៀនប្រហែលប៉ុន្មានឆ្នាំបានគាត់ការគាមអឺស្មាន?

សុខៈ	ប្រហែល ៥ ឆ្នាំ ។

នៃវ៉ាន់ៈ	គាត់រៀបការជាមួយពីណាគេ?

សុខៈ	រៀបការជាមួយវ៉ាត ថិច ។

នៃវ៉ាន់ៈ	រៀបការជាមួយវ៉ាត ថិចហ្អែស៎?

សុខៈ	ចា៎!

នៃវ៉ាន់ៈ	វ៉ាត ថិច ហ្នឹងគាត់អ្នកស្រុកណាដែរ?

សុខៈ	គាត់អ្នកភូមិពោធិ៍តែគាត់នៅម៉ាណោក ។

នៃវ៉ាន់ៈ	បាទ! ពេលគាត់រៀបការហ្នឹងគាត់ស្រឡាញ់ដោយចិត្តឯងឬក៏ម៉ែឪរកអោយ?

សុខៈ	គេដណ្តឹងការត្រឹមត្រូវតើស..។

នៃវ៉ាន់ៈ	បាទ!ប៉ុន្តែ...

សុខៈ	មុនដំបូងវាពេញចិត្តហ្នឹងណា៎ ។

នៃវ៉ាន់ៈ	បា!

សុខៈ	ពេញចិត្តឲ្យម៉ែឪដណ្តឹងការត្រឹមត្រូវទៅ ។

នៃវ៉ាន់ៈ	បាទ! គាត់ឈ្មោះ វ៉ាត ថិចហ្អែស៎?

សុខៈ	ឈ្មោះវ៉ាត ។

នៃវ៉ាន់ៈ	សព្វថ្ងៃនៅរស់ទេ?

សុខៈ	នៅរស់ ។

នៃវ៉ាន់ៈ	គាត់នៅរស់សព្វថ្ងៃនៅអីណា?

សុខៈ	នៅភូមិពោធិ៍ ។

នៃវ៉ាន់ៈ	ឃុំអី?

សុខៈ	ឃុំគារ ។

នៃវ៉ាន់ៈ	ស្រុកមោងឬស្សីដែរ...?

សុខៈ	ចា៎!

នៃវ៉ាន់ៈ	សព្វថ្ងៃគាត់មានគ្រួសាថ្មីដែរហើយ?

សុខៈ	គាត់មាន...មានគ្រួសារថ្មីមានកូន ១ ។

នៃវ៉ាន់ៈ	ដូចថាបន្ទាប់ពីគាត់ការហើយគាត់ប្រកបមុខរបបរអីទៅ?

សុខៈ	គាត់ធ្វើស្រែ ។

នែរ៉ាន់ៈ	អូ..គាត់ធ្វើស្រែធម្មតាទេ...

សុខៈ	ចា៎! ធម្មតា...

នែរ៉ាន់ៈ	គាត់ការហើយរយៈពេលប៉ុន្មានបានគាត់មានកូន?

សុខៈ	ការហើយបាន ១ឆ្នាំ ។

នែរ៉ាន់ៈ	បានកូនប្រុសឬក៏ស្រី?

សុខៈ	បានកូនប្រុស...កូនប្រុសទាំង ២ ណឹង ។

នែរ៉ាន់ៈ	បាទ! ចុះអ៊ីកូនប្រុសគាត់មៅដល់សព្វថ្ងៃណឹងអាយុប៉ុន្មានហើយ?

សុខៈ	អាយុ ២៧...អាបង ២៧ អាប្អូន ២៤ ។

នែរ៉ាន់ៈ	អ៊ីចឹងពេលគាត់ការណឹងរដ្ឋប្រហាហើយឬនៅ?

សុខៈ	ពេលការណឹងនៅឡើយទេ ។

នែរ៉ាន់ៈ	ពេលការណឹងអត់ទាន់រដ្ឋប្រហាទេ?

សុខៈ	ចា៎!

នែរ៉ាន់ៈ	ដល់ពេលគាត់មានកូនគេធ្វើរដ្ឋប្រហាហើយឬនៅ?

សុខៈ	មានកូនអាបងនៅទេ..ដល់អាប្អូនគេរដ្ឋប្រហាហើយ ។

នែរ៉ាន់ៈ	ចឹង ។

សុខៈ	បើអាបងនៅទេ ។

នែរ៉ាន់ៈ	បងមៅទល់សព្វថ្ងៃណឹងអាយុទើបតែ ២៧ ទេ?

សុខៈ	ចា៎! យើមិនមែន ២៧ ទេអាបងនោះអាប្អូនតើសបានអាយុដំណាលមីកូនខ្ញុំនេះ អាបងប្រហែល ៣០ ហើយ ។

នែរ៉ាន់ៈ	៣០ ចាងហើយហ្អែស៎?

សុខៈ	ចា៎! ៣៥ អីទៅ ។

នែរ៉ាន់ៈ	តែកាលគាត់កើតកូនបងណឹងអត់ទាន់រដ្ឋប្រហាទេ?

សុខៈ	ចា៎! នៅឡើយទេ ។

នែរ៉ាន់ៈ	បា!

សុខៈ	បើអាប្អូនកើតបាន ២០ ថ្ងៃរត់បណ្តោយទៅ ។

ណែរ៉ាន់៖ រដ្ឋប្រហារឆ្នាំ ៧០ ហ្អាស៎...ទម្លាក់សម្ដេចហ្អាស៎?

សុខ៖ ចា៎!

ណែរ៉ាន់៖ អីចឹងគាត់កើតកូនបងណឹងមុនរត់ ១ ឆ្នាំ?

សុខ៖ មុន..។

ណែរ៉ាន់៖ អីចឹង ៧៤ អីណឹងហ្អែស៎បានកូនបងណឹង ១?

សុខ៖ បាន ១ ។

ណែរ៉ាន់៖ ពេលគាត់ការហើយគាត់នៅភូមិខាងប្រពន្ធណឹង?

សុខ៖ ការហើយនៅម៉ោណោកណឹង ។

ណែរ៉ាន់៖ បាទ! ធ្វើស្រែចំការជាមួយគ្នាណឹង?

សុខ៖ ចា៎!

ណែរ៉ាន់៖ ចុះគាត់អត់មានដែលចូលបំរើបដិវត្តខ្មែរក្រហមអីទេនែស៎?

សុខ៖ អត់ដែលសោះ កាលណឹងម៉ាហ៊ុករដ្ឋប្រហារណឹងឆ្នាំ ៧១,៧២ អីណឹង ដូចថាគេកែនឲ្យធ្វើទាហានអីចឹងណាស៎ ។

ណែរ៉ាន់៖ បាទ! អូ..កាល ៧១,៧២ ធ្លាប់ទៅធ្វើទាហានដែរ?

សុខ៖ ធ្វើនៅអីណឹងណាស៎...កាលណឹងគេមិនកែនក្នុងភូមិណឹងឲ្យទៅធ្វើទ័ព ។

ណែរ៉ាន់៖ ប្រហែល ៧១,៧២ហ្អែស៎?

សុខ៖ កាលណឹងធ្វើ ៧០ប៉ុន្មានហើយទេ...កាលណឹងវាធ្វើ ៧៤ អីណឹង ។

ណែរ៉ាន់៖ អូ...!

សុខ៖ ទៅបាន ១ ឆ្នាំរដ្ឋប្រហាម៉ងទៅកាលណឹងជិនាន់ណឹង ។

ណែរ៉ាន់៖ បាទ!ធ្វើទាហានខាងណា? ខាងលន់ ណុលឬក៏ខាងខ្មែរក្រហម?

សុខ៖ លន់ ណុល កាលណឹងម៉ោធ្វើបន្ទាយនៅគាលាស់ណឹងណា៎...ដូចថាគេម៉ោកែនប្រជាជនណឹងនៅអត់បាន គេឲ្យធ្វើតែទាំងអស់ណឹងណា៎ បើយើមិនធ្វើគេដេញចាប់ ។

ណែរ៉ាន់៖ អូ...ទាហានលន់ណុលទេ មិនមែនទាហានខ្មែរក្រហមទេ...

សុខ៖ ចា៎! លន់ ណុល កាលណឹងម៉ោធ្វើទាហាននៅគាលាស់ណឹង គេកែនប្រជាជនណឹងនៅមិនបាន អ្នកណាក៏នៅមិនបានដែរ គេឲ្យយើងធ្វើទាំងអស់ណឹងណា៎ បើយើងមិនធ្វើគេដេញចាប់ ។

ឆៃវ៉ាន់: អូ...ទាហានលន់ ណុល ទេមិនមែនទាហានខ្មែរក្រហមផងណឹង?

សុខ: អត់ទេមិនមែនខ្មែរក្រហមទេ ។

ឆៃវ៉ាន់: បាទ!

សុខ: បងខ្ញុំគេអត់ព្រមធ្វើទេ គេឲ្យធ្វើម្ដងបន្តិចៗ នោះ នឹងភូមិណឹងណ៎ា ។

ឆៃវ៉ាន់: អីចឹងគេចាប់ឲ្យគាត់ធ្វើទាហានលន់ ណុលណឹង?

សុខ: ចា៎!

ឆៃវ៉ាន់: មួយឆ្នាំក្រោយមោ៉បានខ្មែរក្រហមចូល?

សុខ: ចា៎! ធ្វើមួយឆ្នាំបានបែករដ្ឋប្រហាឆ្នាំ ៧៥ ណឹងឯង ។

ឆៃវ៉ាន់: បាទ! ដល់ពេលខ្មែរក្រហមចូលមោ៉គេអត់ដឹងប្រវត្តិគាត់ធ្លាប់ធ្វើទាហានលន់ ណុលទេ?

សុខ: ខ្មែរក្រហមហ្អែ៎...

ឆៃវ៉ាន់: បាទ!

សុខ: គេដឹងតើស...ព្រោះអីអាអ្នកគណៈៗណឹងបងប្អូនវាទៅហ្នឹងគគោក ។

ឆៃវ៉ាន់: ហីគេអត់មានចាប់ទេ?

សុខ: គេអត់មានចាប់អីទេ នៅរស់នៅធម្មតាទៅ គេចេះរាប់អានគ្នាធម្មតាទៅ ។

ឆៃវ៉ាន់: អីចឹងពេលខ្មែរក្រហមកាន់បានទាំងអស់ឆ្នាំ ៧៥ ណឹងគេឲ្យទៅនៅឯណាទៅ?

សុខ: មិនដំបូងទៅនៅភូមិសាគរបាន ១ ខែ ។

ឆៃវ៉ាន់: ហើយសាគរណឹងឃុំអីដែរ?

សុខ: ឃុំតាលាស់ហ្អែ៎...

ឆៃវ៉ាន់: ហើយទៅណឹងទៅទាំងអស់គ្នាហ្អែស៎?

សុខ: ចា៎!

ឆៃវ៉ាន់: ទៅនៅហ្នឹងបាន ១ ខែហ្អែស៎?

សុខ: បាន ១ ខែ...ដូចថាបងខ្ញុំមានបងថ្លៃធ្វើគណៈអីចឹងគេឲ្យឡើងមោ៉លើវិញ មោ៉នៅទួលស្ដៅ ។

ឆៃវ៉ាន់: បាទ! ទៅនៅភូមិសាគរបាន ១ ខែណឹងគេឲ្យធ្វើអីខ្លះទៅមីង?

សុខ: គេអត់ឲ្យធ្វើអីទេ អាណឹងដាំបាយដេកស៊ីម៉ង ដល់ពេលហើយគេវៃនៅមោងណឹងនាំគ្នាដឹងស្អីៗយកមោ៉ទុកហូបចឹងណាស់ អត់មានធ្វើអីទេ ។ ដល់ពេល០វន ១ ខែគេឲ្យឡើងទួល

ស្ដេាក្រគេឲ្យធ្វើស្រែ ។

នៃរ៉ាន់: គេយកម៉ែនៅទួលស្ដេាក្រណឹងយកតែគ្រួសារគាត់ឬក៏យកម៉ែទាំងអស់?

សុខ: យកទាំងខ្ញុំអីណឹង ។

នៃរ៉ាន់: ទួលស្ដេាក្រណឹងនៅអីណាវិញ?

សុខ: ទួលស្ដេាក្រណឹង....នៅតាលាស់ដែរជាកន្លែងភ្ជាស្រែតែគេហៅទួលស្ដេាក្រអីចឹងណា?

នៃរ៉ាន់: ពេលគេឲ្យម៉ែនៅទួលស្ដេាក្រណឹងបានគេឲ្យធ្វើស្រែ?

សុខ: ធ្វើស្រែ..ធ្វើស្រែបាន ២ ឆ្នាំ ។

នៃរ៉ាន់: បាទ!

សុខ: ២ ឆ្នាំគេឲ្យឡើងម៉ែនៅត្រស់វិញ ។

នៃរ៉ាន់: អីចឹងឆ្នាំ ៧៥ ណឹងគេឲ្យម៉ែនៅទួលស្ដេាក្រណឹងធ្វើស្រែនៅទួលស្ដេាក្រណឹងបាន ២ឆ្នាំ?

សុខ: បាន ១ ឆ្នាំទេ...បានគេឲ្យឡើងម៉ែនៅអីណោះវិញ ។

នៃរ៉ាន់: បាទ!

សុខ: ឆ្នាំ ៧៦ បានម៉ែនៅត្រស់ណឹង នៅរហូតណឹង ។

នៃរ៉ាន់: ភូមិគ្រោះណឹង?

សុខ: ចាំ!

នៃរ៉ាន់: ហេតុអីបានគេប្ដូរពីស្ដេាក្រម៉ែនៅភូមិត្រស់ណឹង?

សុខ: ទេមិនដឹងដែរ អានេះថាបងថ្លៃខ្ញុំទេមានបងប្អូនគេធ្វើគណៈនៅអាពតណឹងហ្នស៎?

នៃរ៉ាន់: បាទ!

សុខ: ដូចថាបងប្អូនគេៗជម្លៀសឲ្យម៉ែនៅលើវិញម៉ែ ។

នៃរ៉ាន់: ចុះកាលនៅទួលស្ដេាក្រណឹងដូចថា គេឲ្យគាត់ធ្វើការងារអីទៅ?

សុខ: ធ្វើស្រែធម្មតា ។

នៃរ៉ាន់: ធ្វើស្រែជាមួយប្រជាជនយើងណឹង?

សុខ: ចាំ! ធ្វើស្រែ ។

នៃរ៉ាន់: កាលណឹងអ៊ំនៅជាមួយគ្នាណឹង?

សុខ: ចាំ! ធ្វើស្រែទៅខែត្រីនាំគ្នារកត្រីទៅ ។

នៃរ៉ាន់: អូ..! ចុះការងារពិបាកទេ?

សុខៈ ការផ្សាពិបាកចេះតែពិបាកហើយធ្វើអត់ឈប់ផង ហើយក្រោយមៅស៊ីអត់ឆ្អែតវេទនាចង់ស្លាប់ ។

នៃភ៉ន់ៈ នៅទួលស្ដៅណឹង?

សុខៈ នៅទួលស្ដៅអត់អីទេ តែមៅឆ្នាំ ៧៦,៧៧,៧៨ នេះអាណឹងមហាវេទហើយ...។

នៃភ៉ន់ៈ ចឹងកាលនៅទួលស្ដៅណឹងនៅស្រួលនៅឡើយទេ?

សុខៈ ចាំ! នៅស្រួលព្រោះអីយើងនៅស៊ីបរបូនៅឡើយមុនដំបូងអត់ទាន់អីទេ ដល់ឆ្នាំ ៧៦
អត់

បន្ដៗមៅហើយ ។

នៃភ៉ន់ៈ បាទ!

សុខៈ បើខែ ៥ នៅមានគ្រាន់ហូបខ្លះ ដល់ធ្លាក់ដល់ខែពិសាខ ដេសអីណឹងទៅហើយ ។ជួនកាលដាច់បបរនៅគ្រាមពោត,កន្ទុក់ក៏មានដែរ វេទនាណាស់អាឃុំស្ដៅណឹងណាំ ។

នៃភ៉ន់ៈ បាទ!

សុខៈ តែខ្ញុំមិនសូវវេទនាទេខ្ញុំលួចគេបានខ្លះដែរ ។

នៃភ៉ន់ៈ ចុះនៅទួលស្ដៅណឹងអាគរហូបចុកអីគេឲ្យហូបអីទៅ ?

សុខៈ ហូបអីគេចែកបានបន្តិចៗ ។

នៃភ៉ន់ៈ នៅទួលស្ដៅណឹងអត់ទាន់មានសហករណ៍ទេ?

សុខៈ អត់មានទេសហករណ៍មាននៅអីត្រស់ទេ ។

នៃភ៉ន់ៈ អីចឹងកាលឆ្នាំ ៧៥ នៅកន្លែងទួលស្ដៅណឹងអត់មានសហករណ៍ទេ?

សុខៈ អត់មានសហករណ៍ទេ ។

នៃភ៉ន់ៈ អត់ហូបបាយរួមទេអីចឹង?

សុខៈ អត់ទេ នៅឡើយទេ ។

នៃភ៉ន់ៈ អូ...!អត់ហូបបាយរួម...

សុខៈ អាណឹងគេចែកអង្ករឲ្យយើងដាំតាមផ្ទះតាមអីចឹងទៅ ។

នៃភ៉ន់ៈ គេចែកអង្ករតាមផ្ទះតាមអីណឹងរហូតដល់ឆ្នាំណាទៅ ?

សុខៈ អោយមួយឆ្នាំណឹងដល់យើងមៅត្រស់អីណោះអាហ្នឹងគេចែកអង្ករដែរគេអត់ទាន់រួមទេ ។

នៃភ៉ន់ៈ នៅត្រស់ណឹងគេនៅចែកអង្ករទៀត ៧៦ ហើយណឹង?

សុខៈ ចាំ! ចែកអន្ករ ។

នៃរ៉ាន់ៈ អូ.! ហើគាត់មៅហ្នឹងធ្វើស្រែធម្មតាទេ ?

សុខៈ ធ្វើស្រែធម្មតា រកត្រីរកអីដាក់ការដ្ឋានអីចឹងទៅ ។

នៃរ៉ាន់ៈ ចុះពេលធ្វើការនៅទួលស្ដេ។ណឹងគេកំណត់ម៉ោងពេលឲ្យយើងធ្វើយ៉ាងម៉េច?

សុខៈ បើយើធ្វើស្រែអីចឹងចេញពីព្រលឹមទៅភ្លរទៅ ស្រី១ដកស្ទូងអីចឹងទៅ

កាប់ព្រៃកាប់អីចឹង

ទៅ ។

នៃរ៉ាន់ៈ តែការងារពិបាកទេអុំ ?

សុខៈ ការងារធ្វើស្រែមុនដំបូងមិនទាន់ពិបាកទេអារបស់ធ្វើរួមអីចឹងវាអត់ពិបាកទេ វានៅមាន

ហូបចុកគ្រប់គ្រាន់អីចឹងណាស់វាអត់ពិបាកទេ ។

នៃរ៉ាន់ៈ បាទ! តែកាលនៅទួលស្ដេ។ណឹងគេឲ្យហូបបាយឬក៏ហូបបបរ?

សុខៈ បាយនៅឡើយទេ ។

នៃរ៉ាន់ៈ គេចែកមួយគ្រួសារប៉ុន្មានកំប៉ុង?

សុខៈ ដូចថាមួយគ្រួសារ ១ នាក់ ១កំប៉ុង បើ ៥ នាក់ ៥កំប៉ុអីចឹងទៅ ។

នៃរ៉ាន់ៈ កាលណឹងប្រធានសហករណ៍ ប្រធានឃុំគេឈ្មោះអីទៅ ?

សុខៈ កាលណឹងប្រធានសហករណ៍ឈ្មោះរី ។

នៃរ៉ាន់ៈ រី ណឹងស្រីឬប្រុស?

សុខៈ ប្រុស ។

នៃរ៉ាន់ៈ គាត់នៅស្រុកណាដែររីណឹង?

សុខៈ រី អ្នកតាលាស់ដែរ នៅភូមិជាមួយខ្ញុំដែរ ។

នៃរ៉ាន់ៈ ត្រូវបងប្អូនខាងប្រពន្ធ...?

សុខៈ បងប្អូនខាងប្រពន្ធ...ជាប់សាច់ខ្ញុំដែរណឹងមិនមែនអ្នកក្រៅអីគណៈអស់ណឹង ។

នៃរ៉ាន់ៈ ចុះអ្នកផ្សេងអីគេបានហូបដូចគ្នាអីចឹងដែរ?

សុខៈ ដូចគ្នាគេចែកដូចគ្នាអីចឹង ។

នៃរ៉ាន់ៈ ធ្វើនៅទួលស្ដេ។ណឹងបាន ១ ឆ្នាំ?

សុខៈ ចាំ!

ឆៃវ៉ាន់:	៧៦ គេឲ្យម៉ៅនៅត្រស់?

សុខ:	ចា៎! នៅរហូត ។

ឆៃវ៉ាន់:	នៅត្រស់ណឹងធ្វើការរហូតឬក៏ពិបាក?

សុខ:	អាណឹងធ្វើការរវាស់ល្ងាចវាពិបាកដែរណឹងណា៎ ។

ឆៃវ៉ាន់:	នៅផ្ទះណឹងពិបាក?

សុខ:	ចា៎!ពិបាកពេលយើងចុង ៧៦ ចូល ៧៧អីណឹងដូចថាវាអត់ច្រើន អ្នកណាមានហូបមានទៅ អ្នកណាអត់ៗទៅ អ្នកណាចេះរកអីណោះអីណោះទៅ បានហូបគ្រប់គ្រាន់ទៅណា ។

ឆៃវ៉ាន់:	បាទ!

សុខ:	អ្នកដែកគ្មានតំរិះរកបបរទៅ វេទនាណាស់ ឃុំសែវេទនាជាងគេទាំងអស់ ។

ឆៃវ៉ាន់:	អូ..ម៉ៅដល់ត្រស់ណឹងគេហៅឃុំសែ?

សុខ:	ចា៎! នេះគេហៅភូមិសែហើយពិបាកណាស់ស្លាប់ក៏ច្រើនដែរប្រជាជនអត់ឈឺ,អត់បាយ អត់បាយក៏ស្លាប់ដែរ ។

ឆៃវ៉ាន់:	ចុះសម្លាប់អីមានទេ?

សុខ:	សម្លាប់ក៏សម្លាប់ដែរចងទាំងខ្សែៗទៅ ។

ឆៃវ៉ាន់:	អូ..!ចុះកាលណឹងយ៉ាងម៉េចបានគេប្ដូរម៉ៅនៅឃុំត្រស់ណឹងអីចឹង?

សុខ:	អាណឹងដូចថាប្រជាជនថ្មីនោះ ។

ឆៃវ៉ាន់:	អូ..អ៊ំប្រជាជនថ្មីដែរ?

សុខ:	ប្រជាជនថ្មី...ចុហឆ្នាំ ៧៥ គេវ៉ៃបែកមោងហើយបាននាំគ្នារត់អាណឹងបានគេហៅថាប្រជាជនថ្មីអាណឹងយើងនៅ នឹងត្រស់នេះឯង ។ បើប្រជាជនចាស់គេនៅខាងណោះ អាណឹងគេគណៈគេណឹងគេហូបឆ្អែតគេអត់ដែល...បើនៅខាងណោះគេលត់ដំហ្អាស៎ ។

ឆៃវ៉ាន់:	បាទ!

សុខ:	ហើយយើងធ្វើស្រែ ១ ឆ្នាំៗធ្វើអត់ឈប់ទេដល់យើងខែវស្សាអីចឹងគឺថាអត់ហូបច្រើនស្រូវមិនដឹងគេយកទៅណាអស់ទេណា៎ ។

ចឹងបានថាស្រូវមិនដឹងគេយកទៅណាមិនដឹងគេទុក

អីណាទេ ព្រោះអីដំនាន់ណឹងយើងខែអាសាទ,ស្រាព,ភទ្របុត្រ ណឹងវេទនាហើយ ។

ឆៃវ៉ាន់:	បាទ! អ៊ំកាលគេប្ដូបងបស់អ៊ំម៉ៅភូមិត្រស់ណឹង កាលណឹងខាងឃុំគេអ្នកប្ដូរម៉ៅឬក៏ខាង

ណាអ្នកប្អូនម៉ា?

សុខៈ ទេអាណឹងមិនដឹងអីទេ ថាគេចាត់តាំងអីចឹងម៉ង ។

នែរ៉ាន់ៈ តែគ្រួសារអ៊ំ ទេប្អូក៏..

សុខៈ អត់ទេទាំងអស់គ្នា ដល់ក្រោយម៉ាទាំងអស់គ្នាដូចពួកពីភ្នំពេញពីអីចឹងណាស់ ដល់ពួកនេះ ជម្លៀសម៉ាពីភ្នំពេញ ស្វាយរៀង ព្រៃវែង ម៉ាហ្នឹងទាំងអស់ ។

នែរ៉ាន់ៈ ៧៦ ណឹង?

សុខៈ ចាំ!

នែរ៉ាន់ៈ មិនមែន ៧៥ ទេ?

សុខៈ ៧៦ ណឹង...ពួកណឹងម៉ាច្រើនណាស់ ម៉ាពេញតែភូមិណឹង ។

នែរ៉ាន់ៈ ៧៦ ណឹងគេម៉ាគេយកពួកអ៊ំ ម៉ានៅជុំគ្នាហ្នឹងដែរ?

សុខៈ ចាំ! នៅជុំគ្នាទាំងអស់គ្នាណឹង ដូចថាគេម៉ាម៉ាសារៗ អីចឹងណាស់...

នែរ៉ាន់ៈ បាទ!

សុខៈ គេថាជិះរទេះភ្លើម៉ា...គេដាក់នៅ មោងហើយគេបែងចែកទៅណា ដូចថាអង្គការចាត់តាំង យើងឲ្យម៉ាឃុំសែអីចឹងគេម៉ាទៅ ។

នែរ៉ាន់ៈ ហីកាលណឹងអ៊ំ គេហៅ ប្រជាជនថ្មីដែរនៅឡូកឡំគ្នាណឹង?

សុខៈ ចាំ! ខ្ញុំកាលជម្លៀសម៉ា ៧៥ ។

នែរ៉ាន់ៈ ៧៥ ទេ...មិនមែន ៧៦ ទេហ្អែស?

សុខៈ អត់ទេ ៧៥ ទេ ។

នែរ៉ាន់ៈ ៧៥ ទេដែលអ៊ំ ម៉ានៅ ត្រស់ណឹងហ្អែស?

សុខៈ ៧៦ ម៉ានៅត្រស់...៧៥ នៅទួលស្តៅ ។

នែរ៉ាន់ៈ ទួលស្តៅណឹងមានប្រជាជនថ្មីគេជម្លៀសទៅហ្នឹងទេ ពីភ្នំពេញម៉ាហ្អាស?

សុខៈ ពីភ្នំពេញអត់ទាន់មានទេ ។

នែរ៉ាន់ៈ ដល់អ៊ំ ម៉ានៅ ត្រស់ បានមានអ្នកពីភ្នំពេញម៉ា?

សុខៈ ចាំ!

នែរ៉ាន់ៈ ដូចថាកាលអ៊ំ ម៉ានៅ ត្រស់ណឹងគេហៅ អ៊ំ ប្រជាជនថ្មី?

សុខៈ ហីការវេរអ៊ំ ប្រជាជនថ្មី និងការវេរខាងប្រជាជនចាស់...

ឆៃវ៉ាន់: ដូចគ្នា...

សុខៈ អាចាស់គេនៅខាងណោះ អាណឹងសុទ្ធតែថ្មីសុទ្ធហើយណាស៎ ម៉ោពីភ្នំពេញសុទ្ធតែថ្មីហើយណាស៎ ។ ការងាររមានស្អី...ដកស្ទូង ធ្វើស្រែ កាប់ចំការ រែកទឹករែកអី ធ្វើដូចតែគ្នាណឹង ។

ឆៃវ៉ាន់: តែរបបហូបចុកអីស្មេរគ្នាដែរអត់?

សុខៈ ដូចតែគ្នាណឹង គេចែកស្មើតែគ្នាណឹង ដូចថាម្នាក់ ១ កំប៉ុង ១ កំប៉ុងដូចគ្នាអីចឹង ។

ឆៃវ៉ាន់: ចុះបងរបស់អ៊ុំណឹងគេហៅប្រជាជនថ្មីឬក៏ប្រជាជនចាស់?

សុខៈ ដូចគ្នា ។

ឆៃវ៉ាន់: គាត់ណឹងគេហៅប្រជាជនថ្មីដែរ?

សុខៈ នៅជាមួយគ្នាទាំងអស់ណឹង ។

ឆៃវ៉ាន់: កាលម៉ោនៅត្រស់ណឹងនៅដូចថាការងារតឹងរឹងជាងទួលស្ដៅទៀត?

សុខៈ ចា៎! នៅតឹងរឹងព្រោះគេថារួមហ្អស៎ ។

ឆៃវ៉ាន់: កាលណឹងគេមានសហករណ៍ហើយ?

សុខៈ សហករណ៍គេមានអស់ហើយ ដូចថាគេហូបរួមនៅតាមការដ្ឋាន ។

ឆៃវ៉ាន់: កាលអ៊ំ ម៉ោនៅត្រស់ណឹងគេឲ្យហូបបាយឬគេឲ្យហូបបបរ?

សុខៈ អាណឹងវាខែប្រាំងយើងកំពុងធ្វើស្រូវអីចឹងគេឲ្យហូបបាយ ដល់ពេលចុវស្សាយើងហូបបបរទៅ ។

ឆៃវ៉ាន់: អូ..បានបាយខ្លះបបរខ្លះ?

សុខៈ ចា៎! ដល់ពេលយើងអស់អង្ករបបរអីចឹងទៅ គេឲ្យអាគ្រាប់ពោតចែកពោតចែកអីអីចឹងទៅ វាធ្លាក់ដល់កន្ទក់ទៀតណា៎ ។

ឆៃវ៉ាន់: កាលណឹងគណៈឃុំសែឈ្មោះអី?

សុខៈ កានណឹងគណៈឃុំសែគេម៉ោពីណាទេកាលណឹង គណៈគេវាមានច្រើនដែរម៉ោឃុំគេ វាមានប៉ុន្មានគណៈអីណោះ ដូចថាគេចែកការដ្ឋានអីចឹង ។

ឆៃវ៉ាន់: បាទ! គណៈឃុំសែកាលណឹងគេឈ្មោះអីទៅអ៊ំ?

សុខៈ ឃុំសែខ្ញុំដឹងតែឈ្មោះរី... ។

ឆៃវ៉ាន់: រី ក្រែងឃុំតាលាស់អីណោះទេហ្អែស៎?

សុខៈ ឃុំសែយើងណឹង ។

ឆៃវ៉ាន់៖ ចុះតាលាស់យើងណឹងឈ្មោះអី?

សុខ៖ តាលាស់ណឹងហើយត្រស់ណឹង ។

ឆៃវ៉ាន់៖ ចុះអឹំថាឃុំសែដែរ?

សុខ៖ ចា៎! ឃុំសែណឹង,ត្រស់,តាលាស់ ដែរ ។

ឆៃវ៉ាន់៖ ក្រែងមានឃុំតាលាស់ផ្សេងហ្អែស?

សុខ៖ អត់ទេ យើងពីសង្គមគេហៅតាលាស់ ហើយដល់អាពតគេហៅឃុំសែ ។

ឆៃវ៉ាន់៖ ឃុំសែណឹងគេហៅតាលាស់ណឹង...

សុខ៖ ត្រស់អីណឹងតាលាស់ណឹងតែមួយទេ...

ឆៃវ៉ាន់៖ អូ..!ជាមួយគ្នាទេអីចឹង សែ,ត្រស់,តាលាស់ណឹងតែមួយទេអីចឹង?

សុខ៖ ម៉ាខ្សែជាមួយគ្នាទេអាណឹង ម៉ាដួគេរបូតណឹងឃុំសែ ។

ឆៃវ៉ាន់៖ គណៈឃុំគេឈ្មោះ រី?

សុខ៖ អត់ទេ រី ភូមិទេ ។

ឆៃវ៉ាន់៖ ចុះគណៈឃុំគេ?

សុខ៖ ឃុំគេឈ្មោះឈឺន ។

ឆៃវ៉ាន់៖ ឈឺន...

សុខ៖ ចា៎!អាណឹងគណៈឃុំសែណឹងណា៎...ព្រោះអីគណៈឃុំនៅជាប់ផ្ទះខ្ញុំណឹងឯង ដែលហៅបង
ខ្ញុំទៅណឹងប្រពន្ធខ្ញុំម៉ៅហៅហ្អាស៎ ។

ឆៃវ៉ាន់៖ បាទ!ឈ្មោះឈឺន?

សុខ៖ ចា៎!

ឆៃវ៉ាន់៖ គាត់អ្នកស្រុកណាដែរ?

សុខ៖ ថាអ្នកស្រុកកើត...អ្នកភូមិម្ដូអីណាទេមិនដឹងដែរ ។

ឆៃវ៉ាន់៖ អ្នកស្រុកបាត់ដំបងណឹងដែរហ្អែស៎?

សុខ៖ អត់មានបាត់ដំបងទេម៉ៅពីកើត ។

ឆៃវ៉ាន់៖ គាត់ម៉ៅកាន់ហ្នឹងតាំងពី ៧៥ ម៉ៅហ្អែស៎?

សុខ៖ គាត់ម៉ៅកាន់ហ្នឹងតាំង ៧៦ រហូតដល់យួនចូលម៉ៅបានគាត់ចេញ ។

ឆៃវ៉ាន់៖ ចុះគាត់កាលជំនាន់ខ្មែរក្រហមគេឲ្យម៉ៅនៅត្រស់ណឹងគាត់ធ្វើអីទៀតទេ?

សុខៈ ធ្វើអីគេឲ្យដើរបងត្រីបង់អីទៅ ។

នែរ៉ាន់ៈ គេហៅខាងសេដ្ឋកិច្ច...

សុខៈ គេឲ្យខាងបង់ត្រី...

នែរ៉ាន់ៈ រកម៉ៅហួបរកអីណឹងហ្អែស?

សុខៈ ចា៎! រកម្ហូបរកអីណឹង ។

នែរ៉ាន់ៈ ម៉ៅក្រុមគាត់ រកម្ហូបណឹងមានគ្នាប៉ុន្មាននាក់អ៊ំ?

សុខៈ មិនដឹងមានប៉ុន្មាននាក់ដែរមិនដឹងដែរណឹង

ព្រោះអីទៅណឹងចេះថាទៅរកម្ហូបទៅដូចថាពួកគេ

ទៅស្ទូងឆ្ងាយៗ អីចឹងគេដាក់ឲ្យមានអ្នករកត្រីម្នាក់អីចឹងទៅណា៎ ។

នែរ៉ាន់ៈ បាទ!

សុខៈ ដូចថាទៅឆ្ងាយទៅខាងដូនទ្រីអីចឹងគេដាក់អ្នករកត្រីម្នាក់អីចឹងទៅ ។

នែរ៉ាន់ៈ ចុះអ៊ំថាប្រពន្ធគណៈឃុំម៉ៅហៅយ៉ាងម៉េចអ៊ំ?

សុខៈ ម៉ៅហៅថាគេឲ្យហៅ ។

នែរ៉ាន់ៈ ពេលណឹងហៅគាត់នៅឯណាទៅ?

សុខៈ ហៅនៅអីផ្ទះខ្ញុំ ។

នែរ៉ាន់ៈ ឆ្នាំណាដែលគេម៉ៅហៅណឹង?

សុខៈ ចុង ៧៦ កំពង់និយាយគ្នាលេងស្រាប់តែម៉ៅហៅ ។

នែរ៉ាន់ៈ ប្រពន្ធគណៈឃុំណឹងឈ្មោះអីដែរ?

សុខៈ ឈ្មោះ ង៉ែត ។

នែរ៉ាន់ៈ អ្នកស្រុកណាដែរ?

សុខៈ អ្នកស្រុកណឹងជាមួយគ្នាដែរមិនដឹងអ្នកស្រុកណាម៉ៅពីកើតខ្ញុំមិនសូវស្គាល់គេដែរ ។

នែរ៉ាន់ៈ ម៉ៅហៅបងបស់មីងថាម៉េច?

សុខៈ មៅ៉ហៅថាគេឲ្យម៉ៅហៅអីចឹង ។

នែរ៉ាន់ៈ បា! តាំងពីហៅទៅបាត់រហូត?

សុខៈ បាត់រហូត ។

នែរ៉ាន់ៈ អូ..! ណឹងចុង ៧៦ ណឹង?

សុខៈ អាណឹងវាចង់ចូល ៧៧ ហើយ ។

ឆៃវ៉ាន់ៈ អ៊ំមានដឹងថាគេហៅយកទៅណាទេ?

សុខៈ ខ្ញុំអត់ដឹងថាគេហៅយកទៅណាផង ប៉ុន្តែឬគេថាយកទៅលិច គេថាយកទៅដាក់អីកាច់រទេះ គេថាមានកន្លែងគេដាក់មនុស្សនៅកាច់រទេះ ។

ឆៃវ៉ាន់ៈ កាច់រទេះ...?

សុខៈ អាណឹងខ្ញុំចេះតែឬគៗគ្នាដែរទេ តែវាមិនច្បាស់ដែរទេ ។

ឆៃវ៉ាន់ៈ កាលណឹងគាត់ជជែកគ្នាខុសជាមួយអ៊ំហ៊ែ្ន បានប្រពន្ធគណៈឃុំគេមៅហៅ ?

សុខៈ អត់ទេអត់មានជជែកគ្នាខុសទេ អាណឹងដូចថាគំរេងគេ ហីបងខ្ញុំណឹងមានគាត់មិនសូវទប់ ហើយគេប្រកាន់ណាស់ ។ ដូចថានិយាយលេងនិយាយអីចឹងណាស់ អារឿងអីៗខ្ញុំមិនដឹងដែរទេ ។

ឆៃវ៉ាន់ៈ តាមអ៊ំស្មានគេចាប់ដោយសារនិយាយលេងណឹងហ្អែស់?

សុខៈ គេចាប់ណឹងដូចថាប្រឆាំង នឹងគេមិនដឹងអីមិនដឹង ។

ឆៃវ៉ាន់ៈ មិនមែនគេចាប់គាត់ដោយសារអតីតៈ....

សុខៈ គេយកទៅធ្វើអីអត់ហានមាត់កអីទេ ។

ឆៃវ៉ាន់ៈ អីចឹងតាមអ៊ំស្មានកបណឹងគេចាប់ដោយសារ...

សុខៈ ដោយសារនិយាយពាក្យអីដូចថាវាមិនសមរម្យលើគេក៏មិនដឹង ហើយខ្ញុំក៏មិនសូវដឹងដែរណឹងណាស់ ។

ឆៃវ៉ាន់ៈ បាទ! កាលគេមៅយកគាត់ទៅណឹងទៅប៉ុន្មាននាក់?

សុខៈ កាលណឹងទៅតែម្នាក់ឯង ។

ឆៃវ៉ាន់ៈ គេចាប់ម៉ង ឬក៏គេហៅទៅធម្មតា?

សុខៈ គេហៅទៅ គេយកទៅបណ្តោយ ។

ឆៃវ៉ាន់ៈ គេមានចងមានចាប់អីដែរ?

សុខៈ ខ្ញុំអត់ដឹងទេអារឿងចងរឿងចាប់អីខ្ញុំអត់ដឹងទេ ប៉ុនកាលគេហៅយកទៅស្រែកលាខ្ញុំដែរណឹងហ្អាស់ ប្រាប់ថាគេហៅទៅបងលាហើយមើលកូន ២ ណឹងឲ្យខ្ញុំផង ។

ឆៃវ៉ាន់ៈ បាទ!

សុខៈ ខ្ញុំឃើញគេចាប់ដែរគាត់ស្រែកហៅហ្អាស់ ចុះដាប់របងផ្ទះណឹងតើស.. ។

នៃរ៉ាន់: ចុះតាមអ៊ំស្មានពេលគេហៅណឹងអ៊ំគិតថាគេហៅយកទៅធ្វើអីដែរ?

សុខៈ ខ្ញុំថាហៅមុខតែគេយកទៅសម្លាប់ហើយគ្មានយកធ្វើអីទេ ។

នៃរ៉ាន់: ពេលគេហៅក្លាមណឹងអ៊ំគិតថាអីចឹងហ្អែស៎?

សុខៈ ខ្ញុំគិតអីចឹងឯងថាគេសម្លាប់ហើយគេអត់មានទុកទេ... ។

នៃរ៉ាន់: ហេតុអីបានអ៊ំគិតអីចឹង?

សុខៈ គិតអីចឹងខ្ញុំដឹងហើយ ។

នៃរ៉ាន់: ព្រោះឃើញគេពីមុនម៉ៅហ្អែស៎?

សុខៈ ចា៎! ធ្លាគេពីមុនម៉ៅអីចឹងដែរ ។

នៃរ៉ាន់: អ៊ំធ្លាប់ឃើញពីណាដែលគេហៅទៅអីចឹងដែរ?

សុខៈ ខ្ញុំឃើញមិនដឹងពីណាពីណីទេឃើញគេចងដូចថាទៅធ្វើស្រែអីចឹងទៅ ឃើញគេដើរទាំងខ្សែ អីចឹងទៅ ស្រប់តែបាត់អស់ទៅ ។

នៃរ៉ាន់: អូ...! អ៊ំធ្លាប់ឃើញ...?

សុខៈ ចា៎! ធ្លាប់ឃើញតែឃើញពីចម្ងាយទេណា៎អត់ឃើញជិតទេណា៎ ។

នៃរ៉ាន់: កាលណឹងអ៊ំនៅសហករណ៍ណា៎?

សុខៈ នៅសករណ៍ត្រស់ ឃុំសែណឹង ។

នៃរ៉ាន់: ឃើញគេចាប់មនុស្សចងយកទៅ?

សុខៈ ឃើញគេដើរ ៤,៥ នាក់អីចឹងទៅ ហើយស្រប់តែបាត់អស់ទៅ ហៅទៅណឹង ដូចថាតែគេហៅទៅណឹងមុខតែគេយកទៅសម្លាប់ហើយ ។

នៃរ៉ាន់: អ៊ំអ្នកដែលគេហៅយកទៅណឹងអ៊ំមានស្គាល់ទេ?

សុខៈ ខ្ញុំអត់ដឹងទេអ្នកដែលចាប់ណឹងខ្ញុំអត់ដឹងទេ ។

នៃរ៉ាន់: ចុះអ្នកដែលនាំមនុស្សយកទៅណឹងស្គាល់ទេ?

សុខៈ អត់ទេអត់ដែលស្គាល់ទេ ។

នៃរ៉ាន់: អ្នកដែលនាំទៅណឹងភាគច្រើនប្រជាជនចាស់ឬប្រជាជនថ្មី?

សុខៈ អ្នកដែលគេចាប់យកទៅណឹងសុទ្ធតែប្រជាជនថ្មី ។

នៃរ៉ាន់: អីចឹងកាលអ៊ំនៅទួលស្ដៅណឹងអត់មានការចាប់ទេ?

សុខៈ អត់ទេ ។

ផៃរ៉ាន់៖ ទើបមៅនៅ ត្រស់នេះបានឃើញគេចាប់?

សុខៈ ចាំ! ទឹមឆ្នាំ ៧៦,៧៧... ៧៧ ណឹងសម្លាប់ពេញទីហើយ ។

ផៃរ៉ាន់៖ អូ!អីចឹងពួកពីភ្នំពេញគេជម្លៀសមៅដល់នេះ ៧៦ ដើមឆ្នាំ?

សុខៈ ចាំ!

ផៃរ៉ាន់៖ តាមអ៊ំ ឃើញពួកប្រជាជនថ្មីគេចាប់ច្រើនទេ?

សុខៈ ច្រើនដែរណឹង ដូចថាអ្នកខ្លះមានប្តី ធ្វើធំនៅភ្នំពេញអីចឹងណាស់ អាណឹងគេចាប់យកទៅសម្លាប់ គេស្រាវជ្រាវប្រវត្តិរូបអីចឹងទៅដឹង ពេលដឹងទៅ គេចាប់យកទៅសម្លាប់អីចឹងទៅ ។

ផៃរ៉ាន់៖ ចុះអ៊ំមានដែលស្គាល់ប្រជាជនថ្មីដែលគេចាប់យកទៅសម្លាប់ណឹងដែរអត់?

សុខៈ ខ្ញុំភ្លេចអស់ហើយវាយូរហើយ ។

ផៃរ៉ាន់៖ ចុះអ្នកមូលដ្ឋានមានគេចាប់ទៅទេ?

សុខៈ មូលដ្ឋានដល់តែពួកនារតីចូលមៅចាប់ហើយ ។

ផៃរ៉ាន់៖ អូ..! អីចឹងពេលដែលពួកនារតីអត់ទាន់ចូលមៅពួកមូលដ្ឋានណឹងគេអត់ចាប់ទេ?

សុខៈ អត់ទាន់ចាប់ទេ..អាណឹងឆ្នាំចុង ៧៧ ចូល ៧៨ អាណឹងគេផ្តើមចាប់ពួកមូលដ្ឋាន ។

ផៃរ៉ាន់៖ កាលពួកមូលដ្ឋានអត់ទាន់មៅ គេអត់ចាប់ទេ គេចាប់តែអកថ្មី?

សុខៈ ចាំ! អាណឹងគេសម្លាប់តគ្នាណាំ...គិតទៅវាតគ្នា ។

ផៃរ៉ាន់៖ បាទ! ចុះក្រៅពីអ៊ំដឹងថាអ្នកថ្មីគេចាប់ដោយសារមានបងប្អូន គ្រួសារធ្វើទាហាន ធ្វើមន្ត្រីជំនាន់មុនអីចឹង ហឹមានរឿងអីផ្សេងទៀតដែរអត់?

សុខៈ ខ្ញុំមិនសូវដឹងដែរទេ ប៉ុន្តែអ្នកខ្លះធ្វើទាហាន អ្នកធំណឹងគេសម្លាប់ដែរតើស៎ ដូចថាមៅពីភ្នំពេញមៅពីអីណឹងគេសម្លាប់ ។ចុះមានដែលឃើញប្រជាជនថ្មីដែលគាត់លួចអីគេចាប់បានគេយកទៅសម្លាប់ដែរអត់ ។

ផៃរ៉ាន់៖ ទេដែដលមានគេសម្លាប់ដែរតើស ដូចថាលួចអីគេវ៉ៃគេចងទៅ ដូចថាឡើលួចក្នុងឃ្លាំងគេអីចឹងណាំ..មិនលួចស្អីទេ គេចាប់បានគេវ៉ៃ យប់ឡើងស្រែក ។

សុខៈ ស្រីឬប្រុស?

ផៃរ៉ាន់៖ ប្រុស ។

សុខៈ គេធ្វើបាប ។

ណៃរ៉ាន់៖ ហើយបន្ទាប់មកគេលែងវិញទេ?

សុខ៖ គេលែងវិញតើស៎ ។

ណៃរ៉ាន់៖ អ៊ំធ្លាប់ឃើញគេវៃមនុស្សគេធ្វើបាបអីណឹងច្រើនទេ ។

សុខ៖ ខ្ញុំធ្លាប់ឃើញតែម្នាក់ទេ ។

ណៃរ៉ាន់៖ ឈ្មោះអីម្នាក់ដែលអ៊ំឃើញណឹង?

សុខ៖ អូ..ភ្លេចអស់ហើយ ។

ណៃរ៉ាន់៖ ណឹងអ្នកមកពីខាងណាដែរ?

សុខ៖ អ្នកមកពួកថ្មីដែលគ្នាឃ្លានគ្មានអត់អីស៊ីលួចអីចឹងទៅ ។

ណៃរ៉ាន់៖ ពួកមកពីខាងភ្នំពេញហ្អែស៎?

សុខ៖ ចា៎!

ណៃរ៉ាន់៖ លួចអីខ្លះអ៊ំ?

សុខ៖ លួចអង្ករលួចអីណឹង ។

ណៃរ៉ាន់៖ ពេលគេចាប់បានអីចឹងដូចថាគេយកមកប្រជុំឲ្យយើងទ្រជាជនមើលឃើញអត់ទេ?

សុខ៖ អត់ទេអត់មានប្រាប់ប្រជាជនទេ ។

ណៃរ៉ាន់៖ គេចាប់ស្ងាត់ៗអីចឹងម៉ង?

សុខ៖ ចា៎! គេចាប់ទៅជួនកាលគេចងដើមឈើកន្ទែងឃ្វាំងណឹងទៅ ។

ណៃរ៉ាន់៖ អ៊ំធ្លាប់ឃើញគេចងណឹងតែម្នាក់ទេ?

សុខ៖ ម្នាក់ ។

ណៃរ៉ាន់៖ ចុះឃើញគេបណ្តើរមនុស្សណឹងប៉ុន្មានដងដែរ?

សុខ៖ ខ្ញុំឃើញ ២,៣ដងដែរណឹងណា៎..បើម្នាក់នោះប្រពន្ធគណៈដូចថាប្តីគេយក ទៅសម្លាប់ ហើយនៅប្រពន្ធអីចឹង...

ណៃរ៉ាន់៖ ប្រពន្ធគណៈស្រុកហ្អែស៎?

សុខ៖ ប្រពន្ធគណៈភូមិ ។

ណៃរ៉ាន់៖ ពេលនារតីចូលមកណឹងហ្អែស៎?

សុខ៖ ពេលណឹងគេដាក់រទេះទៅ ទៀតណា៎...នេះវៃកន្ទែងខាងកើតនេះទួលខាងកើតណោះ បរទេះ ដឹកទៅមានម្តាយ មានកូន មានប្រពន្ធ ទៅវៃនៅទួលតាឌួកណឹង ។

ឆៃវ៉ាន់: ចុះអ៊ំ ឃើញគេចាប់អ្នកថ្មីទៅ វៃណឹងពួកខាងមូលដ្ឋានអ្នកចាប់ទេ មិនមែនខាងនារតីទេ ។

សុខ: អត់ទេ ។

ឆៃវ៉ាន់: ពួកពាយ័ព្យអ្នកចាប់ ។

សុខ: ចា៎!

ឆៃវ៉ាន់: សុទ្ធតែពួកប្រជាជនថ្មី?

សុខ: ចា៎! ហឺមៅ៉យើងជំនាន់ណឹងអាឆ្នាំ ៧៧ចុង ៧៧ ណឹងហ្អស៎..ពួកប្រជាជណឹងនាំគ្នារត់ ហ្អាស៎...ហើយដល់តែប្តីរត់អីចឹងពេលដែលប្រពន្ធនៅ គេសម្លាប់អស់ហើយអត់ទុកទេ ។

ឆៃវ៉ាន់: ប្តីដឹងថាគេរកចាប់រត់...

សុខ: ប្តីដូចថាឲ្យតែមនុស្សប្រុសគេសម្លាប់ទាំងអស់អីចឹងដល់ពិបាកពេករត់ណាស៎ ។

ឆៃវ៉ាន់: បាទ!

សុខ: ដល់ពេលរត់ចោលប្រពន្ធទៅ ..ប្រពន្ធអីណោះគេសម្លាប់អស់រលីង ។

ឆៃវ៉ាន់: អូ!ចុះកូន?

សុខ: សម្លាប់ទាំងអស់ ។

ឆៃវ៉ាន់: អីចឹងឲ្យតែបីរត់ដឹងតែគេសម្លាប់ប្រពន្ធម៉ង?

សុខ: ចា៎!

ឆៃវ៉ាន់: ចុះបើប្តីអត់រត់គេចាប់តែប្តីទេ?

សុខ: ប្តីអត់រត់អត់អីទេ ។

ឆៃវ៉ាន់: ប្រពន្ធគេអត់យកទៅទេ...?

សុខ: ចា៎! អោយតែរត់គេសម្លាប់អស់ហើយតាំងពីបងប្អូនគេស្រាវជ្រាវ ។

ឆៃវ៉ាន់: អូ..យកតាំងពីបងប្អូនទៀត?

សុខ: មានបងប្អូនក៏គេយកដែរ ។

ឆៃវ៉ាន់: ណឹងពួកនារតីចូលទៅ ហ្អែស៎?

សុខ: ចា៎! នារតី ។

ឆៃវ៉ាន់: អីចឹងឃើញគេបណ្តើមនុស្សពេលអ៊ំកំពង់ធ្វើស្រែណឹងហ្អែស៎?

សុខ: ចា៎!

ឆៃវ៉ាន់: ប្រហែលប៉ុន្មាននាក់ទៅអ៊ំ?

សុខៈ ៤,៥ នាក់ ។

នែរ៉ាន់ៈ ម្ដងៗ ៤,៥ នាក់ ។

សុខៈ ចា៎!

នែរ៉ាន់ៈ គេចងមុខចងអីដែរ?

សុខៈ អត់មានចងទេ បណ្ដើរធម្មតាអីចឹងទៅ ។

នែរ៉ាន់ៈ តាមដឹងថាគេបណ្ដើរណឹងគេយកទៅណាទៅ?

សុខៈ យកទៅវ៉ៃចោល ។

នែរ៉ាន់ៈ កាលណឹងយកទៅវ៉ៃចោលអីណាទៅអ៊ំដឹងទេ?

សុខៈ កាលណឹងយកទៅវ៉ៃចោលនៅប្រឡាយផ្ដៅ វាមានព្រៃគេហៅថាព្រៃខ្មោច ហ្អាស៎..មានដើមត្នោតមានព្រៃអីគេយកទៅវ៉ៃចោលត្រង់ណឹង ។

នែរ៉ាន់ៈ បាទ!អ៊ំដឹងថាគេយកទៅវ៉ៃចោលហ្នឹង?

សុខៈ ដឹង..ដឹងថាគេយកទៅវ៉ៃចោលហ្នឹង ។

នែរ៉ាន់ៈ អ៊ំធ្លាប់ឃើញគេវ៉ៃទេ?

សុខៈ អត់ដែលឃើញទេខ្ញុំមិនដែលឃើញទេ ។

នែរ៉ាន់ៈ អ៊ំដែលស្គាល់អ្នកដែលគេចាប់ណឹងដែរអត់?

សុខៈ អត់ស្គាល់ផង ។

នែរ៉ាន់ៈ ចុះដូចអ្នកធ្វើការជាមួយអ៊ំអីពួកប្រជាជនថ្មីមៅពីភ្នំពេញអីណឹង ដូចថាធ្វើការទៅបាត់មុខបាត់អី បាត់ខ្លួនអី?

សុខៈ អត់អីទេ បើពួកស្វាយរៀងព្រៃវែងអាណឹងបើវាស្រាវជ្រាវរបវត្តិរូបយកទៅវ៉ៃចោលទាំងអស់ឲ្យតែពួកណឹង ហីពួកចាស់យូៗស្លាប់អស់ចេះតែរលួសអស់ឈឺស្លាប់អត់អីស៊ីអីចឹង ។

នែរ៉ាន់ៈ អីចឹងពួកចាស់ណឹងស្លាប់ដោយសារអត់បាយច្រើនជាងហ្អែស៎?

សុខៈ ពួកចាស់អី ពួកថ្មីណឹងហ្អាស៎...

នែរ៉ាន់ៈ អូពួកថ្មីណឹងហ្អែស៎...

សុខៈ ចា៎! អត់បាយផង ឈឺផងណាអត់ថ្នាំលេប ណាពលកម្មវាខ្លាំងផង ម្ល៉ោះហើយស្គមៗទៅងាប់ទៅ ។ ហើយចុងក្រោយបំផុតឲ្យតែអ្នកស្វាយរៀង ។

ណៃរ៉ាន់៖ គេហៅអ្នកបូព៌ាហ្អែស?

សុខ៖ អត់ទេអ្នកស្វាយរៀង ណឹងពួកបូព៌ាណឹងហើយ ។

ណៃរ៉ាន់៖ ពេលពួកនារតីចូលមៅចាប់ពួកណឹងទាំងអស់ម៉ង?

សុខ៖ អត់ទេមិនចាប់ទាំងអស់ទេ គេស្រាវជ្រាវម៉ាសាៗអីចឹងគេសម្លាប់ទៅ ។

ណៃរ៉ាន់៖ អ៊ំមានដែលគេធ្វើទារុណកម្មមនុស្សវ៉ៃអីទេ?

សុខ៖ អត់ដែលឃើញផង ។

ណៃរ៉ាន់៖ ធ្លាប់តែឃើញគេចាប់បណ្តើរទាំងខ្សែៗ?

សុខ៖ ឃើញបណ្តើរណឹង ២ ដងឃើញថ្ងៃល្ងាចកំពុងច្រូតស្រូវ ។

ណៃរ៉ាន់៖ ហីអត់ដែលមៅវិញទេណែស?

សុខ៖ អត់តែទៅបាត់ហើយ ។

ណៃរ៉ាន់៖ អ៊ំមានដែលចំណាំឈ្មោះគេខ្លះទេ?

សុខ៖ អត់ពួកថ្មីខ្ញុំអត់ដែលស្គាល់ឈ្មោះគេផង ។

ណៃរ៉ាន់៖ បាទ!ដល់ចុង ៧៧ ពួកនារតីចូលមៅ?

សុខ៖ ចា៎! ចុង ៧៧ ណឹងហើយនារតីចូលមៅ ។

ណៃរ៉ាន់៖ បាទ! ចូលមៅចាប់ពួកគណៈឃុំចាស់ណឹងទាំងអស់?

សុខ៖ ឲ្យទម្លាក់កាំភ្លើងចេញទាំងអស់...អត់ទាន់ចាប់ទេឲ្យទម្លាក់កាំភ្លើងសិន ។

ណៃរ៉ាន់៖ បាទ!

សុខ៖ យោធាវាមៅពីណោះមៅ ។

ណៃរ៉ាន់៖ ចុះមេឃុំឈ្មោះ រី ណឹង...?

សុខ៖ គេសម្លាប់អស់ហើយ ។

ណៃរ៉ាន់៖ ពួកនារតីណឹងចាប់យកទៅ ...ទាំងប្រពន្ធដែរ?

សុខ៖ ទាំងប្រពន្ធទាំងកូនទាំងអីទាំងអស់ ។

ណៃរ៉ាន់៖ បាទ!គ្រាន់ចូលមៅភ្លាមគេចាប់ម៉ងហ្អែស?

សុខ៖ មេកងអីសម្លាប់ទាំងងស់ ពួកនារតីសម្លាប់ទាំងអស់ មេកងគណៈ...

ណៃរ៉ាន់៖ បន្ទាប់ពីចាប់ទៅពីណាឡើងជំនួស?

សុខ៖ ពួកនារតីណឹងគេឡើង ។

ផៃរ៉ាន់ៈ ឈ្មោះអីទៅ?

សុខៈ ឈ្មោះអីទេខ្ញុំភ្លេចទៅ ។

ផៃរ៉ាន់ៈ ដូចថាពួកនារតីមៅអីចឹងការងារអីការហូបចុកអីខុសពីមុនដែរអត់?

សុខៈ មានខុអី អត់ដូចតែគ្នា ។

ផៃរ៉ាន់ៈ អត់ដដែល?

សុខៈ អត់ដដែល ។

ផៃរ៉ាន់ៈ ពេលណឹងបាយខ្វះបបរខ្វះ?

សុខៈ អាណឹងគេហូបរួមហើយ ។

ផៃរ៉ាន់ៈ តែបានបាយខ្វះទេ?

សុខៈ បាយបានប្រហែល ១ខែអីណឹង ។

ផៃរ៉ាន់ៈ ១ ខែម្តង?

សុខៈ អត់ទេ...យើងថាបាយត្រឹ ១ខែអីណឹងធ្លាក់មៅបបរវិញទៅណា បាយពេលអាកំពុងច្រូតស្រូវណឹងបាយ ។

ផៃរ៉ាន់ៈ ពេលពួកនារតីចូលមៅណឹង?

សុខៈ ពួកនារតីពួកអីណឹងយ៉ាងយូរ ១ខែ ២ខែណឹងបានបាយ រួចពីណឹងបបរទៅ ។

ផៃរ៉ាន់ៈ ចុះការងារអីគេកំណត់តឹងជាងមុនឬក៏យ៉ាងម៉េច?

សុខៈ ការងារធ្វើដូចតែគ្នាអីចឹងឯង ។

ផៃរ៉ាន់ៈ អូរអីចឹងអត់ខុសគ្នាទេ?

សុខៈ អត់ខុសទេ ។

ផៃរ៉ាន់ៈ ប៉ុន្តែកាលណឹងពួកនារតីមៅមានចាប់ពួកប្រជាជនថ្មីដែរអត់ទេ?

សុខៈ ប្រជាជនថ្មីអត់ទេ ។

ផៃរ៉ាន់ៈ លែងចាប់ហើយ ។

សុខៈ ចា៎!អាណឹងគេលេងអាចាស់ម្តង ពួកថ្មីគេតំកើងហើយ ។

ផៃរ៉ាន់ៈ ចុះអ៊ំថាពួកមៅពីស្វាយរៀងអីនោះ?

សុខៈ អាណឹងពេលពួកមៅស្វាយរៀង ពួកនារតីណឹងហើយវាសម្លាប់នោះ ។

ផៃរ៉ាន់ៈ អីចឹងចូលមៅចាប់ពួកមូលដ្ឋាននៅស្រុកភូមិណឹងហើយ បានចាប់ពួកមៅពីស្វាយរៀងព្រៃ

វែង ។

សុខៈ អាណឹងវាមិនដឹងមានរឿងអ៉ីវយ៉ាងម៉េច អាណឹងគេថាពួកស្វាយរៀងព្រៃវែងណឹងត្រូវដៃ ដើងជាមួយយួន ។

ឆែវ៉ាន់ៈ អូ...គេនិយាយអីចឹង?

សុខៈ ចា៎! អីចឹងបានវាខឹងវាបានវាសម្លាប់ ។

ឆែវ៉ាន់ៈ អីចឹងឲ្យតែអ្នកម៉ៅពីព្រៃវែងស្វាយរៀងវាសម្លាប់ទាំងអស់?

សុខៈ ចា៎!

ឆែវ៉ាន់ៈ ពួកព្រៃវែងស្វាយរៀងដែលជម្លៀសម៉ៅនៅត្រស់ណឹងប្រហែលប៉ុន្មាន?

សុខៈ ទេមិនដឹងផង ។

ឆែវ៉ាន់ៈ ច្រើនហ្អែស៎?

សុខៈ ច្រើន ។

ឆែវ៉ាន់ៈ ស្លាប់ទាំងអស់ហ្អែស៎?

សុខៈ ស្លាប់អតមាននៅរស់ទេ ។

ឆែវ៉ាន់ៈ ហីយកទៅសម្លាប់នៅអីណាតាអ៊ំដឹង?

សុខៈ កាលណឹងដឹងសម្លាប់អីណាអត់ដឹងដែរ ប៉ុនថាគេបញ្ជូនទៅណោះទៅណោះអីចឹងទៅណា.. តាមពិតយកទៅសម្លាប់ទេពួកណឹងនោះគេថាពួកណឹងចូលដៃយួន ។

ឆែវ៉ាន់ៈ អ៊ំមានស្គាល់ពួកម៉ៅពីព្រៃវែងស្វាយរៀងដែលគេចាប់ទៅណឹងទេ?

សុខៈ ចាប់វាភ្លេចអស់ហើយ ។

ឆែវ៉ាន់ៈ អត់ចាំទេនែស?

សុខៈ អត់ ។

ឆែវ៉ាន់ៈ អីចឹងពួកនារតីម៉ៅចាប់ខ្លាំងម៉ងនែស៎?

សុខៈ ចាប់...ប្រវត្តិរូបធ្វើម៉ាឆ្នាំដឹងប៉ុន្មានដង ។

ឆែវ៉ាន់ៈ អូ..!គេឲ្យអ៊ំធ្វើប្រវត្តិរូបដែរ?

សុខៈ ធ្វើតែទាំងអស់គ្នាណឹង ។

ឆែវ៉ាន់ៈ គេធ្វើសួរយើងពីអីខ្លះ?

សុខៈ

គេសួរយើងទីលំនៅ នៅអីណា..ថាមុខរបបរអី..រកស៊ីអីចឹងណាស់...ប្រវត្តិរូបណឹងដូចថាមា

ន

បងប្អូនប៉ុន្មាននាក់អីចឹងណា ។ធ្វើប្រវត្តិរូបហើយដឹងថាអ្នកព្រៃវែងយកទៅសម្លាប់អស់

យើង មិនមែនអ្នកព្រៃវែងគេអត់សម្លាប់ទេ ។

នៃរ៉ាន់ៈ អីចឹងប្រវត្តិរូបណឹងធ្វើច្រើនតែពួកនារតីចូលមៅទេ?

សុខៈ កាលនៅអាគណៈមុននោះវាធ្វើដែរតើស់ ។

នៃរ៉ាន់ៈ ម៉ាឆ្នាំធ្វើម្តងហ្អែស់?

សុខៈ មិនដឹងធ្វើប៉ុន្មានដងទេឃើញតែធ្វើ បន្តិចៗ ធ្វើ ..បន្តិចថាថ្នាក់លើឲ្យធ្វើ ។

នៃរ៉ាន់ៈ អ៊ីចាំទេប្រវត្តិរូបណឹងគេសួរយើងពីអីខ្លះ?

សុខៈ ថាស្រុកកំណើតយើងនៅឯណា...មានបងប្អូនប៉ុន្មាននាក់ របបររកស៊ីធ្វើអី..អីចឹងណាស់ ។

នៃរ៉ាន់ៈ បាទ!

សុខៈ យើងប្រាប់ថាធ្វើស្រែធ្វើអីអីចឹងទៅ បងប្អូនប៉ុណ្ណេះនាក់ៗអីចឹងទៅ ។ ហើយយើងជំនាន់

ណឹងមានធ្វើទាហានអត់..។

នៃរ៉ាន់ៈ ចុះអ៊ីគិតថាគេធ្វើប្រវត្តិរូបណឹងដើម្បីអីទៅ?

សុខៈ ដើម្បីស្ទឹមុនដំបូងអត់ដឹង ដល់ពេលចុងក្រោយបានគេថាជ្រើសរើសសម្លាប់ម៉ង ។

នៃរ៉ាន់ៈ អូ!ពេលគេធ្វើណឹងអ៊ីអត់ដឹងដែរ?

សុខៈ មុនដំបូងខ្ញុំអត់ដឹងដែរ ។

នៃរ៉ាន់ៈ ពេលគេធ្វើណឹងអ៊ីអត់ដឹងទេ?

សុខៈ ចាំ!ដូចថាអ្នកណាធ្វើទាហានសក្តិប៉ុន្មានៗអី ដល់យកទៅ បាត់អាអ្នកធ្វើណឹងទៅ

ដឹងគេយក

ទៅណាមៅណី មានតែយកទៅសម្លាប់ដូចថាបាត់អីចឹងទៅ អាអ្នកធ្វើធំៗ គេសម្លាប់ ។

នៃរ៉ាន់ៈ អីចឹងពេលពួកនារតីចូលមៅ នឹងពួកពាយ័ព្យ

នេះកាន់ពីណាគេដែលសម្លាប់ខ្លាំងជាងគេ?

សុខៈ សម្លាប់ខ្លាំងមានតែនារតីហ្នឹងហ្អើយ ។

នៃរ៉ាន់ៈ នារតីណឹង...

សុខៈ ដូចថាពួកគណៈយើងនេះវាមានអត់ឱនអោយខ្វះ ដូចថាបើយើងធ្វើអី...គេមានអត់ឱនឲ្យ
តើស ដូចថាយើងសាច់ឈាមយើងបងប្អូនរបស់យើងអីចឹងណាស់ ។

ផៃរ៉ាន់ៈ បាទ!

សុខៈ ដល់ពួកនារតីមៅគ្មានសល់ទេ ។

ផៃរ៉ាន់ៈ ជាពិសេសពួកមៅពីស្វាយរៀងព្រៃវែងណឹង?

សុខៈ ព្រៃវែងសម្លាប់គ្នាគ្មានសល់ទេ ។

ផៃរ៉ាន់ៈ សម្លាប់ទាំងពូជហ្នឹងហ្អែស?

សុខៈ វាគ្មាននៅច្រើនអីប៉ុន្មានទេ ព្រោះវាស្លាប់អត់បាយស្លាប់ នឹងឈឺអស់ហើយ ។

ផៃរ៉ាន់ៈ អូ..កាលពួកនារតីមៅគេមានបែកទេ..ថាពួកមៅពីស្វាយរៀងព្រៃវែងនៅម្ដុំ...

សុខៈ អត់មានបែកទេអាណឹងនៅជាមួយគ្នាទាំងអស់ ។

ផៃរ៉ាន់ៈ តែគ្រាន់ដល់ពេលគេហៅៗទៅ...

សុខៈ ដូចថានៅតាមភូមិអីចឹងយើងនៅចេះតែនៅទៅ

គេបែកឲ្យនៅត្រង់នេះៗអីចឹងចេះតែធ្វើ

ហូរហែរតាមដងស្ទឹងអីចឹងណាស់ អត់មានបែកវណ្ណៈអត់មានអីទេ នៅធម្មតាទាំងអស់គ្នាអី
ចឹងទៅ ។

ផៃរ៉ាន់ៈ ចុះអ៊ំម៉េចដឹងថាពួកនារតីចោទថាពួកបូព៌ាក្បត់ ពួកមៅពីព្រៃវែងស្វាយរៀងក្បត់?

សុខៈ ខ្ញុំឮគេថាដែរក្មួយ ។

ផៃរ៉ាន់ៈ គេអត់មានប្រជុំប្រកាសអីទេហ្អែស?

សុខៈ អត់នានប្រជុំទេគ្រាន់តែដឹងឮតៗ មៅចេះតែថាមៅ ព្រោះអីវាមៅបីណឹងដែរមិនដឹង វាខឹង
យ៉ាងម៉េចបានវាសម្លាប់ឮគេថាចេះតែថាទៅ ប៉ុនតាមពិតប្រហែលជាអីចឹងទេដឹងព្រោះថា
ចូលដៃជាមួយយួន ។

ផៃរ៉ាន់ៈ អ៊ំមានស្គាល់គណៈស្រុកគេទេ?

សុខៈ អត់ស្គាល់ទេគណៈស្រុកគេច្រើនណាស់ ។

ផៃរ៉ាន់ៈ ប្ដូរហូតហ្អែស? កាលណឹងគេហៅស្រុកលេខប៉ុន្មានដែរស្រុកណឹង ស្រុកមៅឬស្សីណឹង?

សុខៈ មិនដឹងស្រុកលេខប៉ុន្មានទេ?

ផៃរ៉ាន់ៈ ចុះនៅតំបន់អីកន្លែងដែលអ៊ំរស់នៅណឹង?

សុខៈ គេហៅតំបន់ ៤ ។

នៃរ៉ាន់ៈ តំបន់ ៤...

សុខៈ តំបន់មានប៉ុន្មាន...គេចែកស្រុកមោងណឹងតំបន់ ៤...មានតំបន់ ២ ។

នៃរ៉ាន់ៈ ចា!អីចឹងមោងណឹងតំបន់ ៤ អ៊ំស្គាល់គណៈតំបន់គេឈ្មោះអីទេ?

សុខៈ ឈ្មោះអីទេព្រោះប្រធានគេចុះមោណឹងច្រើនដែរណាំ ប៉ុនមិនដឹងអាណាប្រធានមិនដឹងអាណាអីទេ ។

នៃរ៉ាន់ៈ ឈ្មោះអីដែរអ៊ំ ?

សុខៈ ឈ្មោះណឹងតាស៊ូ ,តាស៊ុយណឹងគណៈស្រុកគេដែរ ។

នៃរ៉ាន់ៈ អូ!ស៊ូ ,ស៊ុយអីណឹង...

សុខៈ ចាំ! ហីមិនដឹងថាស្រុកគេមានប៉ុន្មាននាក់ បើមិនដឹងដែរណឹងណាំ ។

នៃរ៉ាន់ៈ អូ!ខស្បាចុះមោទេ ។

សុខៈ ចាំ!គេចុះមោដែរណឹងមោប្រជុំ មោអីដែរណឹងយូរៗ គេមោប្រជុំ មោអីដែរណឹងឈ្មោះតាស៊ូ ,តាស៊ុណឹងឯង ខ្ញុំដឹងតែពីរណឹងឯង យូរៗ គេមោប្រជុំម្ដង ។

នៃរ៉ាន់ៈ អ៊ំស្គាល់ទេ.? តាស៊ូ ,តាស៊ុយអ្នកស្រុកណា?

សុខៈ ទេអត់ស្គាល់ទេ ។

នៃរ៉ាន់ៈ រៀងរោគាត់យ៉ាំងម៉េចដែរអ៊ំ ?

សុខៈ រៀងស ។

នៃរ៉ាន់ៈ ខ្ពស់ឬក៏ទាប?

សុខៈ កំពស់ ១,៦ម៉ែត្រអីណឹងរៀងគេវាឡូយៗដែរណឹង ។

នៃរ៉ាន់ៈ គេខស្បាហ៍ចុះមោប្រជុំហ្អែ ?

សុខៈ យូៗ គេមោប្រជុំម្ដង ។

នៃរ៉ាន់ៈ គេប្រជុំជាមួយអ្នកស្រុកណឹងឬក៏ប្រជុំជាមួយគណៈឃុំ ?

សុខៈ ប្រជុំជាមួយប្រជាជនដែរណឹង ជួនកាលគេមោប្រជុំជាមួយគណៈឃុំជួនកាលជាមួយប្រជាជាជន ។

នៃរ៉ាន់ៈ អ៊ំចាំទេគេប្រជុំពីរឿងអីទៅ ?

សុខៈ គេប្រជុំតែពីរឿងបង្កបង្កើនផលអីណឹង ឲ្យយើងសំរុំកធ្វើទំនប់ដីប្រឡាយ បងបង្កើនផល

ស្អីណឹងប្រជុំអីចឹងឯង ដូចថាយើងម្នាក់ៗកុំឲ្យមានកម្មសិទ្ធស្អីៗ គេហៅអារបបសួនតួ

នោះ ។

នៃវ៉ាន់ៈ បាទ! ចុះគេមាននិយាយពីរឿងសីលធម៌អីដែរអត់?

សុខៈ

សីលធម៌គេមាននិយាយដែរតើស...យើងកុំមានខុសសីលធម៌អីចឹងណា៎...ដូចថាស្រីមានប្ដី

អី

ចឹងយើងតស៊ូប្ដីតែមួយអីចឹងកុំឲ្យយើងមានពីរគេសម្លាប់ហើយ ។

នៃវ៉ាន់ៈ ចុះអ៊ំមានដែលដឹងអ្នកដែលខុសសីលធម៌ដែរអត់?

សុខៈ អ្នកខុសសីធម៌ឃើញមាន១ដែរតើសនៅ...

នៃវ៉ាន់ៈ ឈ្មោះអីទៅ?

សុខៈ ឈ្មោះអីទេ...ដូចថាមានប្ដីហើយទៅស្រឡាញ់គណៈគេយកទៅសម្លាប់ ។

នៃវ៉ាន់ៈ ស្រឡាញ់គណៈឃុំ?

សុខៈ ចា៎!

នៃវ៉ាន់ៈ ស្រឡាញ់គណៈ..ចុះគណៈអត់ស្រឡាញ់វិញទេ?

សុខៈ ស្រឡាញ់គណៈភូមិ ដល់ពេលគេដឹងគេសម្លាប់តែទាំងអស់គ្នាណឹង ។

នៃវ៉ាន់ៈ សម្លាប់ទាំងពីរណឹង?

សុខៈ ចា៎!

នៃវ៉ាន់ៈ ពេលណឹងពួកណាសម្លាប់...ពួកនារតីចូលមៅហ្អែស៎?

សុខៈ ពួកនារតី ។

នៃវ៉ាន់ៈ អូ..ពួកនារតីឃើញមានខុសសីលធម៌ហ្អែស៎?

សុខៈ ចា៎!ឃើញសម្លាប់ប៉ុន្មាននាក់ដែរណឹងហ្អែ៎ ។

នៃវ៉ាន់ៈ គេប្រជុំប្រកាស់ដែរឬក៏ម៉េច?

សុខៈ អត់មានប្រកាស់ទេ អត់មានប្រាប់ទេ ។

នៃវ៉ាន់ៈ ចុះម៉េចអ៊ំដឹងថាខុសសីលធម៌ ?

សុខៈ ប៉ុន្តែខ្ញុំដឹងហ្នឹង ។

នៃវ៉ាន់ៈ ខុសមែនហ្អែស៎អ៊ំ?

សុខៈ ខុសមែន ចុះមនុស្សស្រីមនុស្សប្រុសតែគេឃើញប្លែកគេដឹងហើយ គេមើលឬកពាគេដឹងហើយ ខ្ញុំក៏ដឹងដែរ ។

នៃរ៉ាន់ៈ តាមអ៊ីដឹងខុសមែន?

សុខៈ ខុស ។

នៃរ៉ាន់ៈ ហើយគេយកទៅសម្លាប់ទៅ ?

សុខៈ ចាំ! ដូចថាគណៈភូមិណឹងមានប្រពន្ធអីចឹងណាំ..ដូចថាយើងមេមាយហើយយើងទៅស្រឡាញ់គ្នាអីចឹងទៅ ម្លោះហើយគេយកទៅសម្លាប់គេសម្លាប់ទាំងពីអីចឹងទៅ ។

នៃរ៉ាន់ៈ ហីគេអត់មានប្រជុំប្រាប់អ្នកស្រុកអីទេអីចឹង?

សុខៈ អត់មានប្រាប់ទេ ។

នៃរ៉ាន់ៈ គេមានប្រាប់ថាឈ្មោះនេះឈ្មោះនោះខុសទេ?

សុខៈ អត់មានប្រាប់ទេ... ប៉ុន្តែវាមានបាត់ឈ្មោះទាំងអស់...ពួកភ្នំពេញ ។

នៃរ៉ាន់ៈ ខុសជាមួយពីណាទៅ ?

សុខៈ ជាមួយគណៈ ច្រើនតែជាមួយគណៈទេជាមួយប្រជាជនគេមិនហ៊ានទេ ។

នៃរ៉ាន់ៈ អូ..!

សុខៈ ប្រជាជនយើងនៅនេះមិនហ៊ានទេ តែគណៈណឹងឯងវាឡូយវា ។

នៃរ៉ាន់ៈ អីចឹងឲ្យតែខុសសីលធម៌គេយកទៅសម្លាប់?

សុខៈ ចាំ!

នៃរ៉ាន់ៈ ខុសសីលធម៌ដល់កំរិតណាបានគេយកទៅសម្លាប់?

សុខៈ មិនដឹងដល់កំរិតណាទេ ប៉ុន្តែគេតាមដានដឹងគេយកទៅសម្លាប់ ។

នៃរ៉ាន់ៈ ចុះដូចឧបមាថាយើងលួចស្រឡាញ់គ្នាជួបគ្នាអីណឹងសម្លាប់ដែរ?

សុខៈ អាណឹងយើងស្រឡាញ់គ្នាណឹងបានគេថាខុសសីលធម៌ណឹងបានគេសម្លាប់ ។

នៃរ៉ាន់ៈ អីចឹងឲ្យតែថាស្រឡាញ់អត់បានហ្នឹង?

សុខៈ អាណឹងមិនដឹងម៉េច ព្រោះគេតាមដានដឹងហើយបានគេសម្លាប់ ។

នៃរ៉ាន់ៈ អ៊ំធ្លាប់ឃើញគេខុសសីលធម៌ណឹងប៉ុន្មានដងដែរ?

សុខៈ ឃើញ ២ នាក់ ។

នៃរ៉ាន់ៈ អ៊ំចាំឈ្មោះទេពីរនាក់ណឹង?

សុខៈ ពីនាក់ណឹងអត់ចាំទេភ្លេចអស់ហើយ ។

នៃរ៉ាន់ៈ បន្តែខុសសីលធម៌ដឹងតែពីសម្លាប់ហ្នឹង ។

សុខៈ ចាំ!

នៃរ៉ាន់ៈ ចុះអ៊ំ នៅ គ្រស់ណឹងរហូតវៀតណាមចូលហ្អែស៎?

សុខៈ ចុង ៧៨ ។

នៃរ៉ាន់ៈ វៀតណាមចូលមោ៉?

សុខៈ ចាំ!

នៃរ៉ាន់ៈ អ៊ំមានគេគារយកទៅណាទេ?

សុខៈ ខ្ញុំគេគាទៅដល់ជិតឬស្សីក្រាំងអីណោះ ។

នៃរ៉ាន់ៈ ឬស្សីក្រាំងអីណាទៅ?

សុខៈ ទៅអីលើអីណោះ...ទៅ នៅ អីព្រៃគ្មានទឹកគ្មានអីទេ ទៅណឹងទៅឲ្យស្លាប់ហ្នឹង ។

នៃរ៉ាន់ៈ ពួកខ្មែរក្រហមគេគារទៅហ្អែស៎?

សុខៈ ចាំ!ពួកយោធាគេគារទៅ ដេញទៅ ។

នៃរ៉ាន់ៈ អូ!ហីទៅដល់អីទៅអ៊ំ?

សុខៈ ខ្ញុំទៅដល់អាង ១៧ មេសារគេណឹងហ្អាស៎ ។

នៃរ៉ាន់ៈ នៅ អីណាទៅ អាង ១៧ មេសាណឹង?

សុខៈ ជាប់ព្រំប្រទល់ពោធិសាត់

គេឲ្យទៅ នៅឬស្សីក្រាំងតែខ្ញុំអត់ទាន់ទៅខ្ញុំចេះតែនៅវិលវល់ៗ

អីចឹងទៅ គេសំឡុតរកបាញ់រកអីដែរតែអត់ទៅ ។ គេអ្នកមោ៉គេថាឬស្សីក្រាំងមិនដឹងទៅ រកអីគ្មានទឹកគ្មានអីដឹក ទៅនាំឆាប់អីនៅវិលវល់ៗមោ៉វិញមោ៉លួចមោ៉ណឹងគ្នាច្រើន ណាស់ លួចមោ៉ពីណឹង គេថាយួនចូលមោ៉ហើយ មោ៉ជួយរំដោះប្រជាជន..ដល់នេះខ្ញុំ មោ៉ដើរទាំងយប់ណឹងណា ខ្លះបរទេះទៅខ្លះដើរទៅ ហើយមានកែបីមួយនឹមនោះគេធ្វើ គាវអូសដាក់ឥវ៉ាន់ដាក់អង្ករទៅ ។មោ៉ណឹងដាំបាយតាមផ្លូវទៅដើរទាំងយប់ណឹងមោ៉ ។

នៃរ៉ាន់ៈ ឆ្នាំណាអ៊ំ មោ៉ដល់ស្រុកភូមិវិញ?

សុខៈ គិតទៅ ទៅនៅជិត ១ខែដែរ ។

នៃរ៉ាន់ៈ បានឆាប់ដែរ...ចុះអ៊ំ មោ៉ដល់ស្រុកភូមិវិញអ៊ំបាត់បង់បងប្អូនសាច់ញាតិអស់ប៉ុន្មាននាក់ដែរ?

សុខៈ ខ្ញុំបាត់តែឈ្មោះកបមួយណឹង ។

នែវ៉ាន់ៈ បាត់តែមយយណឹងទេ?

សុខៈ បាត់អស់ ២ នាក់ ឈ្មោះ ធឿន ១ ឈ្មោះ កប ១ ។

នែវ៉ាន់ៈ ចុះឪពុកម្តាយ?

សុខៈ ម្តាយខ្ញុំស្លាប់សម័យអាពត ។

នែវ៉ាន់ៈ ឈឺ?

សុខៈ ចា៎!

នែវ៉ាន់ៈ ចុះសាច់ញាតិជីដូនមួយអី..មីងមារអី?

សុខៈ មីងមារអីបាត់ខ្លះដែរណឹង ។

នែវ៉ាន់ៈ អ៊ីដូចថាធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមអីចឹងគិតថាសម័យណឹងយ៉ាំងម៉េចដែរអ៊ំ?

សុខៈ អូ..!សម័យណឹងយ៉ាប់យ៉ឺនណាស់ ។

នែវ៉ាន់ៈ យ៉ាប់យ៉ឺនម៉េចតៅអ៊ំ?

សុខៈ យ៉ាប់យ៉ឺនវីពិបាកណឹងហ្អាស៎ ។

នែវ៉ាន់ៈ ពិបាករឿងអីខ្លះ?

សុខៈ ពិបាកក្រៃណាពិបាក ពិបាករកគ្មានទេជំនាន់ណឹងអត់អីហូប ដូចថារស់នៅវាមិនស្រួល បន់ឲ្យតែគេមៅជួយយើងនិងអាលបានរស់ ។កាលណឹងអ្នកអត់បាយៗឲ្យតែបានបាយជាមួយអំបិលក៏ឆ្ងាញ់ដែរជំនានណឹងពិបាកមែនទែនគ្មានពីណាចង់ទេកាលណឹងនោះ ។

នែវ៉ាន់ៈ ចុះដូចថាអ៊ំធ្លាប់ឆ្លងកាត់សម័យណឹងពិបាកវេទនាអីចឹងអ៊ំមានកូនចៅក្រោយៗអីចឹងអ៊ំមានដែលនិយាយរឿងអីចឹងប្រាប់ទេ...?

សុខៈ និយាយតើសប្រាប់ កូនចៅប្រាប់តើស៎ ។

នែវ៉ាន់ៈ ប្រាប់ថាម៉េចខ្លះ?

សុខៈ ប្រាប់ពីជំនាន់ណឹងប្រាប់ហូរហែរមៅថាពិបាកអីចេះៗ...ហើយវាមើលទូរទស្សន៍វាឃើញវាជឿទៅ ។

នែវ៉ាន់ៈ ដល់ប្រាប់ទៅវាជឿទេ?

សុខៈ ជឿ វាជឿថាជំនាន់ណឹងពិបាកមែន ចុះវារៀនវាដឹងថាជំនាន់ណឹងពិបាកមែនវាជឿតើស៎ ជំនាន់ណឹងជំនាន់ប្រល័យពូជសាសន៍ ។

ផៃរ៉ាន់៖ ចុះអ៊ំដែលស្តាប់ពត៌មានតាមរយៈវិទ្យុទូរទស្សន៍ពីរឿងការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែរអត់?

សុខៈ ខ្ញុំកាលណឹងធ្លាប់ស្តាប់ដែរតើស ។

ផៃរ៉ាន់៖ ស្តាប់តាមណាដែរ?

សុខៈ ស្តាប់តាមទូរទស្សន៍តាមវិទ្យុអីណឹង ។

ផៃរ៉ាន់៖ ឮថាគេមានបង្កើតតុលាការកាត់ទោសខ្មែរក្រហមដែរអត់?

សុខៈ មានតើសខ្ញុំឮតើស៎ ។

ផៃរ៉ាន់៖ ហើយអ៊ំយល់ថាម៉េច?

សុខៈ ទេអាណឹងមិនដឹងយល់ថាម៉េចបើវាធ្វើបាបយើងម្ល៉ឹងៗ ។

ផៃរ៉ាន់៖ បា! ដូចថាអ៊ំចង់ឲ្យគេបង្កើតតុលាការកាត់ទោសមេដឹងនាំជាន់ខ្ពស់ណឹងដែរអត់ទេ?

សុខៈ ខ្ញុំចង់ដែរណឹងវាធ្វើបាបអស់ទាំងពូជអីចេះ ។

ផៃរ៉ាន់៖ អីចឹងអ៊ំគាំទ្រឲ្យមានការកាត់ទោសដែរ?

សុខៈ ចា៎!អោយគេកាត់ទៅ ។

ផៃរ៉ាន់៖ ចំពោះអ៊ំផ្ទាល់អ៊ំចង់ឲ្យគេកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ឬក៏ចងឲ្យកាត់ទោសថ្នាក់ក្រោមដូចជាមេភូមិ មេឃុំ សហករណ៍ដែរ?

សុខៈ ទេអាមេភូមិមេឃុំគ្នាដឹងអីគ្នា អាណឹងថ្នាក់លើគេបញ្ជាគ្នាបើគ្នាមិនធ្វើគ្នារាប់បាត់ហើយ ។

ផៃរ៉ាន់៖ អីចឹងអ៊ំចង់ឲ្យគេកាត់ទោសតែថ្នាក់លើទេ?

សុខៈ ចង់ឲ្យកាត់តែអាខ្ពស់ណឹងដែលវាធ្វើបាបគេបញ្ជាគេនោះ ។

ផៃរ៉ាន់៖ បាទ!

សុខៈ អាណឹងយោបល់ខ្ញុំ តែយោបល់គេមិនដឹងទេ ។

ផៃរ៉ាន់៖ បាទ! ចុះអ៊ំយល់ថាការបង្កើតតុលាការដើម្បីកាតទោសមេដឹងនាំជាន់ខ្ពស់ខ្មែរក្រហមណឹងវាមានប្រយោជន៍អីដែរចំពោះអ៊ំ ហើយនិងអ្នកស្រុកអ្នកភូមិទាំងអស់គ្នាណឹង ។

សុខៈ អាណឹងមិនដឹងថាម៉េទេ ព្រោះមិនសូវចេះនិយាយ ។

ផៃរ៉ាន់៖ ចុះអ៊ំឮថាគេបង្កើតអីចឹងដើម្បីអីទៅ?

សុខៈ អើដើម្បីរកយុត្តិធម៌ឲ្យប្រជាជនដែលស្លាប់ណឹង ។

ផៃរ៉ាន់៖ អីចឹងគេបង្កើតណឹងដើម្បីរកយុត្តិធម៌ឲ្យប្រជាជនដែលស្លាប់ក្នុងរបបខ្មែរក្រហម?

សុខៈ ទាំងខ្ញុំទាំងអីណឹងណា៎ដែលវេទនាទៅវហេមរហាម ធ្លាប់នៅ នេះមានស៊ីមានចុក ដល់ទៅអី
ណោះអត់គេប្រើដូចគោដូចក្របីអីចឹង ។

នែរ៉ាន់ៈ ចុះអ៊ំយល់ថាម៉េដែរចំពោះពាក្យថាយុត្តិធម៌?

សុខៈ យុត្តិធម៌អាណឹងគេរកឲ្យយើងបាត់ទឹងកំហឹងពីមុនមៅ
ដល់ពេលរកយុត្តិធម៌ទៅកំហឹងយើង
រសាទៅ ។

នែរ៉ាន់ៈ អូ..!អ៊ំគិតថាបើរកយុត្តិធម៌បានកំហឹងណឹងរសាដែរហ្អែស៎?

សុខៈ ចា៎! អាណឹងគំនិតខ្ញុំអីចឹងទេ ។

នែរ៉ាន់ៈ បាទ!អីចឹងអ៊ំមានអីចង់បន្ថែមឲ្យពួកខ្ញុំ នូវរឿងរ៉ាវពីសម័យខ្មែរក្រហមទាក់ទងជាមួយបង
របស់អ៊ំ ឬក៏ទាក់ទងពីជីវិតរបស់អ៊ំដែលខ្ញុំអត់បានសួរនាំដែរអត់?

សុខៈ អាណឹងដឹងបន្ថែមថាម៉េចទេ បើនិយាយអស់ហើយ ។

នែរ៉ាន់ៈ បាទ!អីចឹងអរគុណអ៊ំច្រើនហើយដែលបានផ្ដល់ពត៌មានរឿងរបស់បងអ៊ំឈ្មោះ ឡាច កប
ណឹង..អរគុណ ។

សុខៈ ចា៎!

-ចប់-